# កម្រងព្រះធម៌

## សូត្រប្រចាំថ្ងៃ


រៀបរៀងដោយ

**មហាធម្មភណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន**



ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស.២៥៥៨

គ.ស.២០១៤

| | |
|---|---|
| ឈ្មោះសៀវភៅ | កម្រងព្រះធម៌ សូធ្យប្រចាំថ្ងៃ |
| រៀបរៀងដោយ | មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន (ធម្មានន្ទ) |
| កាលបរិច្ឆេទ | ថ្ងៃ សៅរ៍ ៨ កើត ខែ មិគសិរ ឆ្នាំ មមី ឆស័ក ច.ស.១៣៧៦ ត្រូវនឹងថ្ងៃទី ២៩ ខែ វិច្ឆិកា ព.ស.២៥៥៨ |
| ចំនួនបោះពុម្ព | ១.៥០០ ក្បាល |
| បោះពុម្ព | ចែកជាធម្មទានគោរពជូនបុណ្យចំពោះលោកតា ឈុន វ៉ាន់ លោកយាយ នេត ហុង ដែលបានចែកស្ថានទៅហើយ និងជូនចំពោះលោកតា ឧបាសក លន់ ហ៊ាន់ លោកយាយ ឧបាសិកា ឌុន យ៉ៃ ដែលកំពុងមានជីវិតរស់នៅសព្វថ្ងៃ |

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

## បុព្វកថា

*កម្រងព្រះធម៌នេះ ខ្ញុំព្រះករុណា ខ្ញុំបាទបងក្រងទុកសម្រាប់ធ្វើវត្ត សម្រាប់សូធ្យព្រឹក-ល្ងាច ជាបទនមស្ការសរសើរគុណព្រះរតនត្រ័យ និងផ្សាយនូវមេត្តាចិត្ត ចំពោះសព្វសត្វ ។ ធម៌ទាំងនោះ មាន***ធម៌នមស្ការចំពោះព្រះរតនត្រ័យ បទអារាធនាវត្តា**, **កំពូលកណ្ឌាព្រះត្រៃបិដក**, **ធារណបរិត្ត**, **អសីតិមហាសាវក**, **ជីវទានបាថ:**, **មហាមេត្តាបាថ:** (**ធម៌មហាមេត្រី**) **មេត្តាសូត្រ និង ខន្ធដ្ឋានសូត្រ** *ជាដើម ។ ធម៌ទាំងនេះ ជាធម៌ដែលបោរាណាចារ្យទាំងឡាយធ្លាប់សូធ្យបដិបត្តិមក ដូចជា* **ធម៌ជីវទាន**, **ធម៌មហាមេត្រី** *មានកាពល្បីរន្ទឺថា មានអានុភាពស័ក្តិសិទ្ធិអាចជាសះស្បើយពីជំងឺផ្សេងៗ និងជាធម៌ផ្សាយមេត្តាដល់សព្វសត្វ ។ តែធម៌នេះ មិនមានជាទូទៅនោះទេ ហើយមិនធ្លាប់ឃើញព្រះថេរ: ឬអស់លោកណាប្រែជាភាសាសម្រាយទាល់តែសោះ ទើបខ្ញុំព្រះករុណា ខ្ញុំបាទសាកល្បងត្រួតជម្រះភាសាបាលី រួមទាំងប្រែជាភាសាខ្មែរសម្រាយទុកជាគោលសូធ្យប្រចាំថ្ងៃរបស់ខ្លួន ។ ឯធម៌បទសូធ្យដទៃទៀត សុទ្ធតែជាបទពណ៌នាសរសើរគុណព្រះរតនត្រ័យ ដែលមានអត្ថន័យជ្រាលជ្រៅគួរឲ្យជ្រះថ្លា ដែលខ្លួនខ្ញុំព្រះករុណា ខ្ញុំជាអ្នកពេញចិត្តយ៉ាងខ្លាំង ក្នុងការសូធ្យចម្រើនភាវនាព្រះពុទ្ធគុណ ព្រះធម្មគុណ និងព្រះសង្ឃគុណជាប្រចាំ ។ ហេតុដូច្នោះ ទើបប្រមូលជាកម្រងព្រះធម៌មួយ សម្រាប់ខ្លួនឯង ដោយសន្មតឈ្មោះថា កម្រងព្រះធម៌សូធ្យប្រចាំថ្ងៃ។*

*នៅក្នុងខុទ្ទកនិកាយ ធម្មបទគាថា បិដកលេខ ៥២ ទំព័រ ៤៥ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា*

យំ កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វម្បិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជ្ជុគតេសុ សេយ្យោ។

*បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា*

*ជំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ចំពោះលោក ទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។*

**អភិវាទនសីលិស្ស     និច្ចំ វុឌ្ឍាបចាយិនោ**

**ចត្តារោ ធម្មា វឌ្ឍន្តិ     អាយុ វណ្ណោ សុខំ ពលំ។**

*ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចំរើនដល់អ្នក ដែលមានសេចក្ដីឱនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្ដីកោតក្រែង ដល់បុគ្គលដែលចំរើនជាងខ្លួន អស់កាលជានិច្ច ។*

## អានិសង្សចម្រើនពុទ្ធានុស្សតិ

*(ក្នុងគម្ពីរវិសុទ្ធិមគ្គ)*

១.សត្ថរិ សគារវោ ហោតិ សប្បតិស្សោ *ជាអ្នកមានសេចក្ដីគោរព មានសេចក្ដីកោតក្រែងចំពោះព្រះសាស្ដា*

២.សទ្ធាវេបុល្លំ *រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ដោយសទ្ធា*

៣.សតិវេបុល្លំ *រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ដោយសតិ*

៤.បញ្ញាវេបុល្លំ *រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ដោយបញ្ញា*

៥.បុញ្ញវេបុល្លញ្ច អធិគច្ឆតិ *រមែងជាអ្នកបានចំពោះនូវការពេញបរិបូណ៌ ដោយបុណ្យកុសល*

៦.បីតិបាមោជ្ជពហុលោ ហោតិ *ជាអ្នកច្រើនទៅដោយបីតិ និងបាមោជ្ជៈ*

៧.ភយភេរវសហោ ទុក្ខាធិវាសនសមត្ថោ *អត់ធន់ចំពោះភ័យ និងហេតុ ដែលគួរឲ្យខ្លាច ជាអ្នកអាចអត់សង្កត់សេចក្ដីទុក្ខ*

៨.សត្ថារា សំវាសសញ្ញំ បដិលភតិ *រមែងបានចំពោះនូវសេចក្តីសម្គាល់ថា ដូចជាបាននៅរួមជាមួយព្រះសាស្តា*

៩.ពុទ្ធគុណានុស្សតិយា អជ្ឈាវុត្ថញ្ចស្ស សរីរម្បិ ចេតិយឃរមិវ បូជារហំ ហោតិ *សូម្បីសរីរៈរបស់បុគ្គលនោះ ដែលការរលឹករឿយៗ នូវគុណព្រះពុទ្ធគ្រប់គ្រងហើយ ជាកាយគួរដល់ការបូជា ដូចជាផ្ទះនៃចេតិយ*

១០.ពុទ្ធភូមិយំ ចិត្តំ នមតិ *ចិត្តរមែងបង្អោនទៅក្នុងពុទ្ធភូមិ*

១១.វីតិក្កមិតព្វវត្ថុសមាយោគេ ចស្ស សម្មុខា សត្ថារំ បស្សតោ វិយ ហិរោត្តប្បំ បច្ចុបដ្ឋាតិ *មួយវិញទៀត កាលបើមានការជួបប្រសប់ នឹងវត្ថុដែលគួរប្រព្រឹត្តល្មើស ហិរិនិងឱត្តប្បៈ រមែងប្រាកដដល់បុគ្គលនោះ នៅចំពោះមុខ*

១២.ឧត្តរិ អប្បដិវិជ្ឈន្តោ បន សុគតិបរាយនោ ហោតិ *កាលមិនទាន់ចាក់ធ្លុះនូវគុណធម៌ខ្ពង់ខ្ពស់ រមែងជាអ្នកមានសុគតិទៅខាងមុខ ។*

តស្មា ហវេ អប្បមាទំ កយិរាថ សុមេធសោ
ឯវំ មហានុភាវាយ ពុទ្ធានុស្សតិយា សទា។

*ព្រោះហេតុនោះឯង អ្នកមានបញ្ញាល្អ គប្បីធ្វើសេចក្តីមិនប្រមាទ*
*ក្នុងពុទ្ធានុស្សតិ ដែលមានអានុភាពច្រើន យ៉ាងនេះ គ្រប់ៗកាល ។*

*ថ្ងៃសៅរ៍ ៨ កើត ខែ មិគសិរ ឆ្នាំ មមី ឆស័ក ច.ស.១៣៧៦*
*ត្រូវនឹងថ្ងៃទី ២៩ ខែ វិច្ឆិកា ព.ស.២៥៥៨ ។*

**ធម្មាចារ្យ វ៉ាន់ ចាន់សារ៉ែន**

## ការថ្វាយបង្គំ ៣ យ៉ាង

*(គម្ពីរបរមត្ថទីបនី សង្គហមហាដីកា និងនមក្ការដីកា)*

*ការថ្វាយបង្គំមាន ៣ យ៉ាង ដោយចំណែកក្នុងការថ្វាយបង្គំផ្លូវកាយ ជាដើម សម ដូចព្រះពុទ្ធវចនៈថា ៖*

**តិស្សោ ឥមា ភិក្ខវេ វន្ទនា ។ កតមា តិស្សោ ? កាយេន វន្ទតិ, វាចាយ វន្ទតិ, មនសា វន្ទតិ ។**

*ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំមាន ៣ យ៉ាង ។ ៣ យ៉ាងនោះ តើដូចម្តេច ? ការថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១ ។*

*បុគ្គលណាមានចិត្តដ៏ប្រសើរឲ្យតាំងនៅចំពោះមុខ ហើយញ៉ាំងអវយវៈ ទាំង ៥ គឺ ជើង ២ ដៃ ២ ក្បាល ១ ឲ្យតាំងនៅត្រង់ផ្ទៃ ក្រាបចុះចំពោះមុខ អ្នកដែលគួរដល់ការ ថ្វាយបង្គំ ហៅថា* **ថ្វាយបង្គំដោយកាយ** ។

*អ្នកពោលស្វាធ្យាយសម្តែងគុណសម្បត្តិដោយវាចាហៅថា ថ្វាយបង្គំដោយវាចា ដូចពោលថា* **នមោ ពុទ្ធស្ស, នមត្ថុ ពុទ្ធស្ស, នមោ វិមុត្តិយា, នមោ វិមុត្តានំ, វិបស្សិស្ស នមត្ថុ** *ជាដើម ចាត់ជាការ* **ថ្វាយបង្គំដោយវាចា** ។

*ចំណែកការរលឹកដល់គុណសម្បត្តិស្មើ ដោយបណ្តោយតាមពាក្យសម្តែងគុណសម្បត្តិ ហៅថា* **ថ្វាយបង្គំដោយចិត្ត** ។

*បទបាលី ឬគាថាទាំងនេះ ជាបទគាថាដែលគួរដល់កិរិយានមស្ការថ្វាយបង្គំ ចម្រើននូវ ពុទ្ធានុស្សតិ រលឹកដល់គុណនៃព្រះពុទ្ធ, ធម្មានុស្សតិ រលឹកដល់គុណនៃព្រះធម៌, សង្ឃានុស្សតិ រលឹកដល់គុណនៃព្រះសង្ឃ នាំឲ្យយើងបានសម្រេចនូវបុណ្យកុសលរាប់ប្រមាណមិនបាន នឹង បានជាបច្ច័យនាំឲ្យសម្រេចនូវសេចក្តីសុខទាំងបច្ចុប្បន្ន និងបរលោក ជាពិសេសជាបច្ច័យនាំឲ្យ បានដល់ទីដ៏ក្សេមពោល គឺព្រះនិព្វានហោង ។*

**អនុមោទនា ភាវនាចម្រើនព្រះពុទ្ធគុណ ព្រះធម្មគុណ និងព្រះសង្ឃគុណ !**

# មាតិកាអត្ថបទ

**មាតិកា** **ទំព័រ**


| មាតិកា | ទំព័រ |
|---|---|
| *បទសរភញ្ញ* | *១* |
| *បូជាព្រះរតនត្រ័យ(សីសំ មេ បទុមំ កត្វា)* | *២* |
| *រតនត្តយបូជា (ឥមេហិ ទីបធូបា)* | *២* |
| *នមស្ការ បទបប្បាវត្ត (នមោ ៨ បទ)* | *៣* |
| *នមោ ៣ បទ* | *៣* |
| *នមោ ៣ បទ រួបរួមជា ១ បទ* | *៤* |
| *នមស្ការចំពោះព្រះពុទ្ធជាមហានាគ* | *៤* |
| *នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ* | *៥* |
| *ពុទ្ធរតនប្បណាម* | *៨* |
| *ធម្មរតនប្បណាម* | *១១* |
| *សង្ឃរតនប្បណាម* | *១៣* |
| *បារមីទាំង ៣០* | *១៨* |
| *នមស្ការព្រះពុទ្ធ ៧ ព្រះអង្គ* | *២២* |
| *នមស្ការព្រះពុទ្ធ ២៨ ព្រះអង្គ* | *២៤* |
| *ព្រះពុទ្ធគុណ ៧ អង្គ (វិបស្សី ពុទ្ធោ...)* | *២៥* |
| *នមស្ការព្រះពុទ្ធនាមកែសជ្យគុរុ* | *២៧* |
| *ធារណបរិត្ត* | *២៨* |
| *គាថាជិនបញ្ជរ* | *៣១* |
| *មន្តកំពែងព្រះរតនត្រ័យ* | *៣៥* |
| *គាថាមហាទិព្វមន្ត* | *៣៦* |
| *មន្តការពារទាំង ៨ ទិស* | *៣៦* |
| *ធាតុចេតិយនមក្ការគាថា* | *៣៧* |
| *អាការវត្តា (ធម៌អាការវតា)* | *៣៩* |
| *កំពូលកណ្ឌព្រះត្រៃបិដក* | *៥១* |
| *អសីតិមហាសាវក (ធម៌នមស្ការមហាសាវក ៨០ អង្គ)* | *៧០* |

| | |
|---|---|
| ជីវទានបាឋៈ (ធម៌ជីវទាន) | ៧២ |
| មហាមេត្តាបាឋ (ធម៌មហាមេត្រី) | ៨៣ |
| មេត្តាសូត្រ (អានិសង្សផ្សាយមេត្តា) | ៩២ |
| ឧដ្ឋានសូត្រ (ធម៌អ្នកចូរក្រោកឡើង) | ៩៦ |
| សរណទីបិកាគាថា (ធម៌សម្តែងអំពីទីពឹងដ៏ប្រសើរ) | ៩៨ |
| ទលិទ្ទសុត្តគាថា (ធម៌សម្តែងអំពីការមិនក្រ) | ៩៩ |
| គារវសុត្តគាថា (ធម៌សម្តែងអំពីការគោរពព្រះសទ្ធម្ម) | ១០០ |
| បព្វតោបមសុត្តគាថា (ធម៌ឧបមានឹងភ្នំថ្ម) | ១០១ |
| សំវេជនីយគាថា (ន គាមធម្មោ ជាដើម) | ១០៣ |
| សេចក្តីដាស់តឿនរបស់ព្រះពុទ្ធបរមគ្រូ | ១០៧ |
| មន្តគាថាសេកទឹកមន្ត | ១១១ |

# បទសរភញ្ញ

សូមថ្វាយបង្គំ-ព្រះសម្ពុទ្ធ ប្រសើរបំផុត-ក្នុងលោកា
ជាគ្រូនៃមនុស្ស-និងទេវតា ទ្រង់ត្រាស់ទេសនា-ប្រដៅសត្វ
ចង្អុលឲ្យដើរ-ផ្លូវកណ្ដាល មាគ៌ាត្រកាល-អាចកម្ចាត់
ទុក្ខភ័យចង្រៃ-ឲ្យខ្ចាយបាត់ អាចកាត់សង្សា-រះទុក្ខបាន ។
សាសនាព្រះអង្គ-នៅសព្វថ្ងៃ សត្វមាននិស្ស័យ-ពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់-ចេះចាំបាន កាន់តាមលំអាន-បានក្ដីសុខ
ឥតមានសុខណា-ស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខ-ឃ្លាតចាកទុក្ខ
តាំងពីលោកនេះ-តទៅមុខ ក្ដីសុខនឹងមាន-ព្រោះធម៌ស្ងប់ ។
ខ្ញុំសូមបង្គំ-ធ្មោះព្រះធម៌ ព្រះសង្ឃបវរ-ទាំងគ្រប់សព្វ
រួមជាត្រៃរត្ន-គួរគោរព ជាម្លប់ត្រជាក់-នៃលោកា
ព្រះរូបព្រះធាតុ-នៃព្រះពុទ្ធ វិសុទ្ធតាងអង្គ-ព្រះសាស្ដា
សូមគុណត្រៃរត្ន-ជួយខេមរា ឲ្យបានសុខា-តរៀងទៅ ។

# បូជាព្រះរតនត្រ័យ

**សីសំ មេ បទុមំ កត្វា ទីបញ្ច នយនទ្វយំ**

**វចសា ធូបការេន មនសា ច សុគន្ធិកំ ។**

*ខ្ញុំសូមឱនសិរសា ទុកជាផ្កាឈូកឧត្តម*

*និងភ្នែកទាំងពីរផ្សំ ទុកជាគ្រឿងប្រទីបថ្វៃ ។*

*ព្រមទាំងសុវាចា ខ្ញុំធ្វើជាធូបប្រពៃ*

*ចិត្តនឹកព្រះរតនត្រ័យ ទុកជាក្លិនក្រអូបហោង ។*

## រតនត្តយបូជា

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

*ប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះ { ពុទ្ធ / ធម៌ / សង្ឃ } ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយមានទៀន និងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយមានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។*

# នមស្ការ បទបថ្យាវត្ត

## នមោ ៨ បទ

**នមោ អរហតោ សម្មា- សម្ពុទ្ធស្ស មហេសិនោ**

*សូមថ្វាយបង្គំចំពោះព្រះអរហន្ត សម្ពុទ្ធភគវន្តកាលស្វែករកធម៌*
*គឺពោធិញ្ញាណប្រសើរបវរ បានត្រាស់ដឹងធម៌ដោយអរិយមគ្គ ។*

**នមោ ឧត្តមធម្មស្ស ស្វាក្ខាតស្សេវ តេនិធ**

*សូមថ្វាយបង្គំព្រះធម៌ឧត្តម ដែលព្រះបរមសម្ពុទ្ធសម្តែង*
*ដោយប្រពៃពិតប្រាកដជាក់ស្តែង ព្រះធម៌នោះឯងទុកក្នុងសាសនា ។*

**នមោ មហាសង្ឃស្សាបិ វិសុទ្ធសីលទិដ្ឋិនោ**

*សូមថ្វាយបង្គំព្រះសង្ឃប្រសើរ ដែលលោកបានធ្វើទិដ្ឋិនិងសីល*
*ឲ្យបានបរិសុទ្ធផុតចាកមន្ទិល គឺទិដ្ឋិសីលលោកស្អាតអស់ហើយ ។*

**នមោ ឱមាត្យារទ្ធស្ស រតនត្តយស្ស សាធុកំ**

*សូមថ្វាយបង្គំប្រជុំត្រៃរត្ន ប្រារព្ធដោយបទមានបីប្រការ*
*ព្រះពុទ្ធព្រះធម៌ព្រះសង្ឃឈ្នះមារ ប្រសើរអស្ចារ្យប្រឹងថ្លែងពុំបាន ។*

**នមោ ឱមកាតីតស្ស តស្ស វត្ថុត្តយស្សបិ**

*សូមថ្វាយបង្គំក្ជុំវត្ថុបី ពិសេសពិសីប្រសើរថ្កើងថ្កាន*
*ព្រះពុទ្ធព្រះធម៌ព្រះសង្ឃសព្វឋាន ជយឬកល្យាណដោយគុណគួរគាប់ ។*

**នមោភាវប្បតាវេន វិគច្ឆន្តុ ឧបទ្ទវា**

*សូមថ្វាយបង្គំត្រៃរត្នសោភា ឧបទ្រពនានាចូរវិនាសបាត់*
*ដោយអានុភាពបុណ្យជួយកម្ចាត់ ធ្វើក្តីវិបត្តិឲ្យស្ងាត់សូន្យទៅ ។*

**នមោភាវានុភាវេន សុវត្ថិ ហោតុ សព្វទា**

*សូមថ្វាយបង្គំត្រៃរត្នទាំងបី សូមសុខសួស្តីកើតសព្វវេលា*
*ដោយអានុភាពធ្វើការវន្ទា គោរពបូជាចំពោះព្រះត្រៃរត្ន ។*

**នមោភាវស្ស តេជេន វិធិម្ហិ ហោមិ តេជវា ។**

*សូមថ្វាយបង្គំត្រៃរត្នសោភា តេជះចេស្តាសូមមានដល់ខ្ញុំ*
*ក្នុងពិធីធ្វើកិច្ចថ្វាយបង្គំ តេជះបុណ្យធំសូមកើតមានឡើង ។*

## នមោ ៣ បទ

**នមោ តស្សារហន្តស្ស ភគវន្តស្ស តាទិនោ**
**សម្មា សាមំវ ពុទ្ធស្ស ធម្មេ វិតជ្ជវាទិនោ។**

*សូមថ្វាយបង្គំចំពោះព្រះអរហន្ត ទ្រង់ព្រះនាមភគវន្តប្រសើរបវរ*

ព្រះអង្គមិនមានព្រះទ័យញាប់ញ័រ ដោយលោកធម៌ទាំង ៨ ឡើយ
ទ្រង់ត្រាស់ដឹងធម៌ដោយប្រពៃហើយ ចែកធម៌នោះឲ្យដល់សត្វទាំងពួង ។

**នមោ តស្សេវ ធម្មស្ស និយ្យានិកស្ស វគ្គតោ**
**បភេទា នវវិធស្ស ស្វាក្ខាតស្សេវ សច្ចតោ ។**

សូមថ្វាយបង្គំចំពោះគុណព្រះធម៌ ស្រង់សត្វនិករចេញចាកសង្សារ
ជាធម៌មានភេទ ៩ ប្រការ ដែលសាស្ដាចារ្យពោលទុកទូន្មាន
មានព្រះសោតានោះជាប្រធាន មានព្រះនិព្វានជាបរិយោសាន ។

**នមោ អរិយសង្ឃស្ស សញ្ឆិន្នតស្ស សត្ថុនោ**
**កិលេសានុសយេ សព្វេ បហានប្បដិបត្តិយា ។**

សូមថ្វាយបង្គំចំពោះគុណព្រះសង្ឃ ប្រសើរគ្រប់អង្គ ជាសិស្សសាស្ដា
ជាសង្ឃប្រតិបត្តិលះកាត់តណ្ហា ព្រះទ័យជ្រះថ្លា គ្មានសៅហ្មងឡើយ
អនុសយកិលេសលោកលះអស់ហើយ និងឆ្លងដល់ត្រើយ គឺព្រះនិព្វាន ។

**នមោ ៣ បទ រួបរួមជា ១ បទ**

**នមេ ពុទ្ធំ តិលោកគ្គំ ញេយ្យសាគរបារគុំ**
**តថាគតករំ ធម្មំ គណាញ្ញ គុណាសាគរំ ។**

សូមថ្វាយបង្គំនូវព្រះសម្ពុទ្ធ ប្រសើរខ្ពស់ផុតសត្វក្នុងលោក
ព្រះអង្គមានញាណជ្រាលជ្រៅប្រាជ្ញព្រោក ហើយព្រះទ្រង់ជោគដល់ត្រើយសាគរ ។
សូមថ្វាយបង្គំព្រះធម៌បវរ ញ៉ាំងសត្វនិករឲ្យឆ្លងចាកភព
សូមថ្វាយបង្គំព្រះសង្ឃជាម្ចប់ គុណគួរគោរពដូចសាគរធំ
តេជានុភាពផលថ្វាយបង្គំ សូមឲ្យយើងខ្ញុំបានសុខសព្វកាល ។

## នមស្ការចំពោះព្រះពុទ្ធជាមហានាគ

**សេដ្ឋោ តថាគតោ លោកេ ពុទ្ធនាគោតិ វិស្សុតោ**
**នាគេន ទេសិតោ ធម្មោ និយ្យានិកោតិ សញ្ញិតោ**
**តស្សាបិ សាវកោ សង្ឃោ សន្តិន្ទ្រិយោ អនាសវោ**
**នាគំបិ បាបកំ អាគុំ តស្មា នាគោតិ វុច្ចរេ ។**

ព្រះតថាគតវិសុទ្ធក្នុងលោក ព្រះអង្គមានជោគលើសលោកទាំង ៣
ព្រះនាមពុទ្ធនាគជាពាក្យបាលី អស់ជនប្រុសស្រីគប្បីដឹងច្បាស់ ។
ថាជាព្រះនាមព្រះពុទ្ធជាម្ចាស់ ប្រសើរពេកណាស់លើសមនុស្សទេពតា
ព្រះធម៌ដែលព្រះពុទ្ធនាគទេសនា ប្រោសអស់ទេវតាមនុស្សទាំងឡាយ

*ជាធម៌ស្រង់សត្វឲ្យផុតអបាយ　　អ្នកប្រាជ្ញទាំងឡាយលោកបានជ្រាបច្បាស់*
*ព្រះអរិយសង្ឃសាវ័កច្រើនណាស់　　ជាសង្ឃនៃព្រះពុទ្ធនាគជាធំ ។*
*សង្រួមឥន្ទ្រិយស្រគត់ស្រគំ　　កិលេសតូចធំក្សិណក្ស័យអស់ហើយ*
*លោកឈប់ស្រឡះគ្មានប៉ះពាល់ឡើយ　　ព្រះសង្ឃនេះហើយដែលទ្រង់ប្រទាន ។*
*នាមថានាគោទុកជាប្រធាន　　ព្រោះលោកពុំមានធម៌ដ៏លាមក*
*លោកឈប់ស្រឡះលែងធ្វើអាក្រក់　　ព្រះលោកនាយកព្រះពុទ្ធនាគនោះ ។*
*ទ្រង់ប្រោសប្រទាននាគោជាឈ្មោះ　　ជាពាក្យពីរោះចំពោះពុទ្ធដីកា*
*ដោយមានគម្ពីរព្រះមុនីទេសនា　　ប្រារព្ធនិងកាឡុទាយីនោះ ។*

**វន្ទេហំ ពុទ្ធនាគញ្ច　　ធម្មំ នាគេន ទេសិតំ**
**នាគស្សារិយសង្ឃញ្ច　　មហានាគន្តិ វិស្សុតំ**
**ពុទ្ធនាគាទិតេជេន　　ឧប្បន្នា ចេ ឧបទ្ទវា**
**រោគា ចេវន្តរាយា ច　　វិនស្សន្តុ អសេសតា ។**

*យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំ　　ចំពោះព្រះបរមពុទ្ធនាគផង*
*ចំពោះព្រះធម៌ប្រសើរកន្ទង　　ដែលព្រះច្បាស់ច្បងពុទ្ធនាគសម្តែង ។*
*និងព្រះអរិយសង្ឃព្រមទាំងគម្តែង　　មាននាមជាក់ស្តែងហៅមហានាគោ*
*ជាទីសាវ័កមានថ្នាក់សេដ្ឋោ　　ព្រះពុទ្ធនាគោប្រទានទុកមក ។*
*តេជះរតនត្រៃថ្លាថ្លៃពន្លក　　យើងខ្ញុំសូមជ្រកក្រោមម្លប់សាខា*
*មានព្រះពុទ្ធនាគជាដើមថ្លៃថ្លា　　ទោះរោគភយាឧបទ្រពអន្តរាយ*
*ដែលកើតមានឡើងឲ្យប៉ើងខ្ចាត់ខ្ចាយ　　សូមឲ្យរលាយវិនាសបាត់ទៅ*
*បើពុំទាន់មានឲ្យខានទៅក្រៅ　　ចៀសចេញឆ្ងាយទៅកុំនៅរៀងអាយ ។*
*សូមសុខសព្វកាលត្រអាលសប្បាយ　　សម្បត្តិទាំងឡាយសម្បូរណ៍ឥតខ្វះ*

## នមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ

**វន្ទេ តណ្ហង្ករំ ពុទ្ធំ　　វន្ទេ មេធង្ករំ មុនឹ**
**សរណង្ករំ មុនឹ វន្ទេ　　ទីបង្ករំ ជិនំ នមេ ។**
**វន្ទេ កោណ្ឌញ្ញសត្ថារំ　　វន្ទេ មង្គលនាយកំ**
**វន្ទេ សុមនសម្ពុទ្ធំ　　វន្ទេ រេវតនាយកំ ។**
**វន្ទេ សោភិតសម្ពុទ្ធំ　　អនោមទស្សឹ មុនឹ នមេ**
**វន្ទេ បទុមសម្ពុទ្ធំ　　វន្ទេ នារទនាយកំ ។**
**បទុមុត្តរំ មុនឹ វន្ទេ　　វន្ទេ សុមេធនាយកំ**
**វន្ទេ សុជាតសម្ពុទ្ធំ　　បិយទស្សឹ មុនឹ នមេ។**

**អត្ថទស្សឹ មុនឹ វន្ទេ ធម្មទស្សឹ ជិនំ នមេ**
**វន្ទេ សិទ្ធត្ថសត្ថារំ វន្ទេ តិស្សមហាមុនឹ។**
**វន្ទេ បុស្សមហាវីរំ វន្ទេ វិបស្សិនាយកំ**
**សិខឹ មហាមុនឹ វន្ទេ វន្ទេ វេស្សភូនាយកំ ។**
**កកុសន្ធំ មុនឹ វន្ទេ វន្ទេ កោណាគមនំ ជិនំ**
**កស្សបំ សុគតំ វន្ទេ វន្ទេ គោតមនាយកំ ។**
**អដ្ឋវីសិតិមេ ពុទ្ធា និព្វានាមតទាយកា**
**នមេ តេ សិរសា និច្ចំ តេ មំ រក្ខន្តុ សព្វទា ។**

*ខ្ញុំសូមបង្គំព្រះបរមសម្ពុទ្ធ មាននាមប្រាកដព្រះតណ្ហង្ករ*
*ខ្ញុំសូមបង្គំព្រះបរមបវរ ព្រះមេធង្ករជាសម្ពុទ្ធា ។*
*សូមក្រាបបង្គំប្រណម្យវន្ទា នូវព្រះភគវាព្រះសរណង្ករ*
*សូមថ្វាយបង្គំព្រះទីបង្ករ មានញាណបវរបារមីពោរពេញ ។*
*សូមថ្វាយបង្គំនូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញធម៌ជាកុសល*
*ខ្ញុំសូមបង្គំនូវព្រះទសពល ព្រះនាមមង្គលជាសម្ពុទ្ធៈ ។*
*ខ្ញុំសូមបង្គំប្រណម្យគារវៈ ព្រះនាមសុមនៈសម្មាសម្ពុទ្ធ*
*ខ្ញុំសូមបង្គំព្រះបរមសុគត ព្រះនាមប្រាកដព្រះរេវតៈ ។*
*ខ្ញុំសូមបង្គំព្រះបរមពុទ្ធៈ មានញាណសោភៈ ព្រះនាមសោភិត*
*ខ្ញុំសូមបង្គំប្រណម្យប្រណិត ឆ្ពោះព្រះវិជិតអនោមទស្សី ។*
*ខ្ញុំសូមក្រាបថ្វាយឱនកាយសិរសើចំពោះព្រះមុនីព្រះនាមបទុម*
*ខ្ញុំសូមឱនកាយថ្វាត់ថ្វាយបង្គំ ចំពោះព្រះបរមព្រះនាមនារទៈ ។*
*សូមថ្វាយបង្គំព្រះបរមបទុមុត្តរៈ មានញាណសោភៈវរពេទា*
*ខ្ញុំសូមបង្គំនូវព្រះភគវា ទ្រង់ព្រះនាមាសុមេធសម្ពុទ្ធ ។*
*ខ្ញុំសូមបង្គំប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធព្រះនាមសុជាត*
*ខ្ញុំសូមបង្គំប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថបិយទស្សី ។*
*ខ្ញុំសូមបង្គំឆ្ពោះព្រះជិនស្រី អត្ថទស្សីបារមីខ្ពង់ខ្ពស់*
*ខ្ញុំសូមបង្គំឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះធម្មទស្សី ។*
*ខ្ញុំសូមបង្អោនលំទោនសិរសើ បង្គំជិនស្រីព្រះនាមសិទ្ធត្ថ*
*ខ្ញុំសូមបង្គំនូវព្រះមុនីរតន៍ ព្រះនាមប្រាកដតិស្សសាស្ដា ។*
*ខ្ញុំសូមបង្គំនូវព្រះសម្មា- សម្ពុទ្ធនាមជាបុស្សមុនី*

ខ្ញុំសូមបង្គំប្រណម្យអញ្ជលី ឆ្ពោះព្រះមុនីព្រះនាមវិបស្សី ។
សូមថ្វាយបង្គំបរមជិនស្រី ព្រះនាមសិខីសពេ៌ជ្ញពុទ្ធា
ខ្ញុំសូមឱនកាយក្រាបថ្វាយវន្ទា ឆ្ពោះព្រះភគវាព្រះនាមវេស្សភូ ។
សូមបង្គំលើកហត្ថទាំងគូ ឆ្ពោះព្រះជាគ្រូនាមកកុសន្ធៈ
ខ្ញុំសូមបង្គំប្រណម្យគារវៈ ឆ្ពោះព្រះពុទ្ធៈកោណាគមនោ ។
ខ្ញុំសូមឱនកាយវាចាទន់ទោរ បង្គំពុទ្ធោព្រះនាមកស្សបៈ
ខ្ញុំសូមលន់ទោរបង្អោនសិរៈ ជាទីគារវៈព្រះនាមគោតម ។
គម្រប់ម្ភៃប្រាំបីព្រះបរម- សម្ពុទ្ធជាធំកំពូលលោកា
ទូទាំងត្រៃភពជាម្លប់សាខា មនុស្សសត្វទេវតាមារព្រហ្មទាំងឡាយ ។
ដែលបានចូលជ្រកក្រោមម្លប់ព្រះធាយ បានសុខសប្បាយគ្រប់រូបរាល់គ្នា
បានទៅសោយសុខក្នុងឋានសួគ៌ា ឬឋានព្រហ្មានិងព្រះនិព្វាន ។
ដោយបុណ្យបារមីនៃព្រះទ្រង់ញាណ ព្រះធម៌ប្រធានជាយាននាំសត្វ
តេជះយើងខ្ញុំប្រណម្យថ្វាយថ្វាត់ នូវព្រះពុទ្ធរតន៍គ្រប់ៗព្រះអង្គ ។
ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គម្ភៃប្រាំបី
ខ្ញុំសូមអានុភាពពីព្រះជិនស្រី ម្ភៃប្រាំបីព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ព្រះអង្គសម្តែង ទាំងព្រះគម្តែងសង្ឃជាសាវ័ក
សូមសុខចម្រើនកើតឡើងតាមថ្នាក់ កុំឲ្យមានអាក់រាងរាល់ជាតា ។
សូមឲ្យខ្ញុំបានដល់ឋានទេវតា ដូចក្តីប្រាថ្នាកុំបីឃ្លៀងឃ្លាត
មានព្រះនិព្វានជាអវសានជាតិ កុំឲ្យខ្ញុំឃ្លាតពីព្រះនិព្វានហោង ។

## ពុទ្ធរតនប្បណាម

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស។

*(សូត្រ ៣ ដង)*

*ប្រែថា* *រីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគ អង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។*

*(ក្រាបថ្វាយបង្គំម្តង)*

យោ សន្និសិន្នោ វរពោធិមូលេ

មារំ សសេនំ មហតឹ វិជេយ្យោ

សម្ពោធិមាគច្ឆិ អនន្តញាណោ

លោកុត្តមោ តំ បណមាមិ ពុទ្ធំ ។

*ប្រែថា* *ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គ នោះដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្តង)*

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា

បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ។

*ប្រែថា* *ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងកប្បនេះក្តី*

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ
នោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។**

<u>ប្រែថា</u> **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោល គឺកិលេសព្រមទាំងវាសនា គឺកាយ-បយោគ និងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅ ព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាម ថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច

ហើយ ញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវប្រកាសប្តេជ្ញាខ្លួនចំពោះព្រះពុទ្ធគុណថា៖

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ។**

<u>ប្រែថា</u> **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើរបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជ័យមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

(ក្រាបថ្វាយបង្គំម្តង)

រួចហើយត្រូវសូមខមាទោសនឹងព្រះពុទ្ធគុណដូច្នេះថា៖

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

<u>ប្រែថា</u> **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

**ធម្មវន្ទនប្បណាម**

អដ្ឋង្គិកាវិយបថោ ជនានំ

មោក្ខប្បវេសាយ ឧជូ ច មគ្គោ

ធម្មោ អយំ សន្តិករោ បណីតោ

និយ្យានិកោ តំ បណមាមិ ធម្មំ ។

*<u>ប្រែថា</u> ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឲ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឲ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឲ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្តង)*

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា

បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។

*<u>ប្រែថា</u> ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធដែលនឹងមាន មកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណាដែលជាធម៌របស់ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយ នោះគ្រប់កាលទាំងពួង ។*

*(ក្រាបថ្វាយបង្គំម្តង)*

*គួរបង្អោនកាយវាចា ហើយតាំងចិត្តរឭកដល់ព្រះធម្មគុណថា៖*

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

*ប្រែថា* **ស្វាក្ខាតោ ភគវតា ធម្មោ** *ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ* **ធម្មោ** *ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១* **សន្ទិដ្ឋិកោ** *ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង* **អកាលិកោ** *ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ* **ឯហិបស្សិកោ** *ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន* **ឱបនយិកោ** *ជាធម៌គឺព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា* **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** *ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។*

*(ក្រាបថ្វាយបង្គំម្តង)*

*ប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា៖*

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

*ប្រែថា* **នត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ* **ធម្មោ មេ សរណំ វរំ** *មានតែព្រះធម៌ជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើរ*

*របស់ខ្ញុំ ព្រះករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គលចូរមាន ដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

*(ក្រាបថ្វាយបង្គំម្តង)*

*រួចហើយត្រូវសូមខមាទោសនឹងព្រះធម្មគុណថា៖*

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។**

*<u>ប្រែថា</u>* **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរ មានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង* **ធម្មេ យោ ខលិតោ ទោសោ** *ទោសឯណាដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់* **ធម្មោ ខមតុ តំ មមំ** *សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

*(ក្រាបថ្វាយបង្គំម្តង)*

### សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**គុណេហិនេកេហិ សមិទ្ធិបត្តោ**

**អនាសវោ តំ បណមាមិ សង្ឃំ ។**

*<u>ប្រែថា</u> ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិលគឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវធម៌មិនមាន គឺថា*

*ជាព្រះទីណាស្រេត ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃ នោះ ដោយគោរព ។*

*(ក្រាបថ្វាយបង្គំម្តង)*

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា**

**បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។**

*ប្រែថា ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃ នឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលក្នុងកាលជាបច្ចុប្បន្ន នេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះ គ្រប់កាលទាំងពួង។*

*(ក្រាបថ្វាយបង្គំម្តង)*

*រួចហើយគប្បីតាំងចិត្តរឭកដល់ព្រះសង្ឃគុណដោយបន្អោនកាយវាចាថា៖*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិ-ករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

<u>ប្រែថា</u> **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេមផុតចាកទុក្ខទាំងពួង

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា

**យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១

**អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១

**ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវក នៃព្រះដ៏មានព្រះភាគ

**អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា

**បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិ និងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា

**ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា

**អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យ នៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។

(ក្រាបថ្វាយបង្គំម្តង)

តទៅគប្បីប្រកាសប្តេជ្ញាខ្លួនចំពោះព្រះសង្ឃគុណថា ៖

**នត្ថិ មេ សរណំ អញ្ញំ　　សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន　　ហោតុ មេ ជយមង្គលំ ។**

<u>ប្រែថា</u> **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណា មិនមានឡើយ

**សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើររបស់ខ្ញុំព្រះករុណា

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តី ជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

រួចហើយត្រូវសូមខមាទោសនឹងព្រះសង្ឃគុណថា ៖

**ឧត្តមង្គេន វន្ទេហំ　　សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ　សង្ឃោ ខមតុ តំ មមំ ។**

*ប្រែថា* **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរ មានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តម គឺត្បូង*

**សង្ឃេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឲ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់*

**សង្ឃោ ខមតុ តំ មមំ** *សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។*

*(ក្រាបថ្វាយបង្គំម្តង)*

## បារមីទាំង៣០

**ឥតិបិ ទានបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ បរិបូណ៌ហើយដោយទានបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ទានឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានឧបបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ ទានបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយទានបរមត្ថបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ សីលបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ សីលឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលឧបបារមី មែនព្រោះហេតុដូច្នេះ។*

**ឥតិបិ សីលបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសីលបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ នេក្ខម្មបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មាព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយនេក្ខម្មបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ បញ្ញាបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបញ្ញាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ បរិបូណ៌ហើយ ដោយវិរិយបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវិរិយឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ វិរិយបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយវិរិយបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គ បរិបូណ៌ហើយ ដោយខន្តីបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិឧបបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តីឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ខន្តិបរមត្ថបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយខន្តីបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចបារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយសច្ចឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សច្ចបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយសច្ចបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ អធិដ្ឋានបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគ-អង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយអធិដ្ឋានបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ មេត្តាបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយមេត្តាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាឧបចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាឧបបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ឧបេក្ខាបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយឧបេក្ខាបរមត្ថបារមី មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ ទសចារមិសម្បន្នោ ទសឧបចារមិសម្បន្នោ ទសបរមត្ថចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមី១០ បរិបូណ៌ហើយ ដោយឧបបារមី១០ បរិបូណ៌ហើយដោយបរមត្ថបារមី១០ មែនព្រោះហេតុដូច្នេះ ។*

**ឥតិបិ សមត្តឹសចារមិសម្បន្នោ សោ ភគវា** *ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ហើយ ដោយបារមីទាំង៣០ មែនព្រោះហេតុដូច្នេះ ។*

## នមស្ការព្រះពុទ្ធ ៧ ព្រះអង្គ

វិបស្សិស្ស ច នមត្ថុ ចក្ខុមន្តស្ស សិរីមតោ
សិខិស្សបិ ច នមត្ថុ សព្វភូតានុកម្បិនោ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី*
*ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការថ្វាយបង្គំ*
*ចំពោះព្រះសម្ពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តី*
*អនុគ្រោះដល់សត្វទាំងពួងជាប្រក្រតី ។*

វេស្សភុស្ស ច នមត្ថុ ន្ហាតកស្ស តបស្សិនោ
នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម*
*វេស្សភូ ព្រះអង្គមានកិលេសលាងស្អាតហើយ*
*ព្រះអង្គមានតបធម៌ សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធ*
*ទ្រង់ព្រះនាមកកុសន្ធៈ ព្រះអង្គញាំញីនូវមារព្រមទាំងសេនា*
*នៃមារ ។*

កោណាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ
កស្សបស្ស ច នមត្ថុ វិប្បមុត្តស្ស សព្វធិ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម*
*កោណាគមនៈ ព្រះអង្គមានបាបបន្សាត់ចោលហើយ*
*មានព្រហ្មចរិយធម៌នៅរួចហើយ សូមនមស្ការថ្វាយបង្គំ*
*ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ព្រះអង្គផុតចាក*
*កិលេសទាំងពួងហើយ ។*

អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ
យោ ឥមំ ធម្មំ ទេសេសិ សព្វទុក្ខាបនូទនំ។

*សូមនមស្ការថ្វាយបង្គំ ចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាម អង្គីរសៈ ព្រះអង្គជាបុត្រនៃសក្យរាជ ដ៏មានសិរី ព្រះសម្ពុទ្ធអង្គឯណា ទ្រង់បានត្រាស់សម្តែងហើយនូវធម៌នេះ ជាធម៌បន្ទោបង់នូវទុក្ខទាំងពួង ។*

យេ ចាបិ និព្វុតា លោកេ យថាភូតំ វិបស្សិសុំ

តេ ជនា អបិសុណាថ មហន្តា វីតសារទា។

*មួយទៀត ព្រះសម្ពុទ្ធទាំងឡាយអង្គឯណា ព្រះអង្គរំលត់កិលេសហើយក្នុងលោក ទ្រង់ឃើញច្បាស់នូវធម៌តាមសេចក្តីពិត ព្រះសម្ពុទ្ធទាំងឡាយនោះ ព្រះអង្គមិនមានសេចក្តីញុះញង់ស៊កសៀត ទ្រង់ប្រសើរដោយព្រះគុណមានសេចក្តីក្រវល់ក្រវាយ(ព្រោះកិលេស)ទៅប្រាសហើយ។*

ហិតំ ទេវមនុស្សានំ យំ នមស្សន្តិ គោតមំ

វិជ្ជាចរណសម្បន្នំ មហន្តំ វីតសារទំ។

*ទេវតានិងមនុស្សទាំងឡាយ រមែងនមស្ការ នូវព្រះសម្ពុទ្ធអង្គឯណាជាគោតមគោត្រ ជាប្រយោជន៍ដល់ទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈប្រសើរ ដោយព្រះគុណមានសេចក្តីក្រវល់ក្រវាយ(ព្រោះកិលេស) ទៅប្រាសហើយ ។*

## នមស្ការព្រះពុទ្ធ ២៨ ព្រះអង្គ

នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ
តណ្ហង្ករោ មហាវីរោ មេធង្ករោ មហាយសោ ។

*ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះ គឺ)ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ ព្រះមេធង្ករ ព្រះអង្គមានយសធំ ។*

សរណង្ករោ លោកហិតោ ទីបង្ករោ ជុតិន្ធរោ
កោណ្ឌញ្ញោ ជនបាមោក្ខោ មង្គលោ បុរិសាសភោ ។

*ព្រះសរណង្ករ ព្រះអង្គធ្វើឲ្យជាប្រយោជន៍ដល់សត្វលោក ព្រះទីបង្ករព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន ព្រះមង្គលៈព្រះអង្គជាបុរសដ៏ប្រសើរ ។*

សុមនោ សុមនោ ធីរោ រេវតោ រតិវឌ្ឍនោ
សោភិតោ គុណសម្បន្នោ អនោមទស្សី ជនុត្តមោ ។

*ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ ព្រះរេវតៈ ព្រះអង្គញុំាងសេចក្តីត្រេកអរឲ្យចម្រើន ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ដោយព្រះគុណ ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន ។*

បទុមោ លោកបជ្ជោតោ នារទោ វរសារថិ
បទុមុត្តរោ សត្តសារោ សុមេធោ អប្បដិបុគ្គលោ ។

*ព្រះបទុមៈ ព្រះអង្គញុំាងលោកឲ្យភ្លឺស្វាង ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពពួកសត្វ ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន ។*

សុជាតោ សព្វលោកគ្គោ    បិយទស្សី នរាសភោ

អត្ថទស្សី ការុណិកោ    ធម្មទស្សី តមោនុទោ។

*ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង*
*ព្រះបិយទស្សីព្រះអង្គប្រសើរជាងនរជន ព្រះអត្ថទស្សី ព្រះអង្គ*
*ប្រកបដោយករុណា ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត ។*

សិទ្ធត្ថោ អសមោ លោកេ    តិស្សោ ច វទតំ វរោ

បុស្សោ ច វរទោ ពុទ្ធោ    វិបស្សី ច អនូបមោ។

*ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក*
*ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសម្តីទាំងឡាយ*
*ព្រះពុទ្ធទ្រង់ព្រះនាមបុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ*
*ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ។*

សិខី សព្វហិតោ សត្ថា    វេស្សភូ សុខទាយកោ

កកុសន្ធោ សត្ថវាហោ    កោណាគមនោ រណញ្ជហោ

កស្សបោ សិរិសម្បន្នោ    គោតមោ សក្យបុង្គវោ ។

*ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឲ្យជាប្រយោជន៍ដល់សត្វទាំងពួង*
*ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វ*
*ចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស ព្រះកោណាគមនៈ ព្រះអង្គបំបាត់បង់*
*នូវសត្រូវ គឺកិលេស ។ ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី*
*ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ។*

**ព្រះពុទ្ធគុណ ៧ អង្គ**

**១- វិបស្សី ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។** *ព្រះពុទ្ធព្រះនាម វិបស្សី ដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យដ៏ច្រើន មានញាណ ដ៏ច្រើន មានគុណដ៏ច្រើន មានតេជៈដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាព ដ៏ច្រើន ។*

**២- សិខី ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ។** *ព្រះពុទ្ធព្រះនាម សិខី ដ៏មានព្រះភាគ ជា*

*ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់មានបុណ្យដ៏ច្រើន មានញាណដ៏ច្រើន មានគុណដ៏ច្រើន មានតេជះដ៏ ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាពដ៏ច្រើន ។*

**៣-វេស្សភូ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ៕** *ព្រះពុទ្ធព្រះនាម វេស្សភូ ដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះ អង្គទ្រង់មានបុណ្យដ៏ច្រើន មានញាណដ៏ច្រើន មានគុណដ៏ច្រើន មានតេជះ ដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាពដ៏ច្រើន ។*

**៤- កកុសន្ធោ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ៕** *ព្រះពុទ្ធព្រះនាម កកុសន្ធោ ដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យដ៏ច្រើន មានញាណដ៏ច្រើន មានគុណដ៏ច្រើន មាន តេជះដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាពដ៏ច្រើន ។*

**៥- កោណាគមនោ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ៕** *ព្រះពុទ្ធព្រះនាម កោណាគមនោ ដ៏មានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យដ៏ច្រើន មានញាណដ៏ច្រើន មានគុណដ៏ច្រើន មាន តេជះដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាពដ៏ច្រើន ។*

**៦- កស្សបោ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ៕** *ព្រះពុទ្ធព្រះនាម កស្សបោ ដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យដ៏ច្រើន មានញាណដ៏ច្រើន មានគុណដ៏ច្រើន មាន តេជះដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាពដ៏ច្រើន ។*

**៧- អម្ហាកំ ពុទ្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ អនន្តបុញ្ញោ អនន្តញាណោ អនន្តគុណោ អនន្តតេជោ អនន្តឥទ្ធិ អនន្តជុតិ ៕** *ព្រះពុទ្ធជាម្ចាស់នៃយើង ដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គ ទ្រង់មានបុណ្យដ៏ច្រើន មានញាណដ៏ច្រើន មានគុណដ៏ច្រើន មាន តេជះដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាពដ៏ច្រើន ។*

**សត្តិមេ ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តបុញ្ញា អនន្តញាណា អនន្តគុណា អនន្តតេជា អនន្តឥទ្ធិមន្តា អនន្ត-ជុតិមន្តា៕** *ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ នោះ ដ៏មានព្រះភាគ ជាព្រះ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មានបុណ្យ ដ៏ច្រើន មានញាណដ៏ច្រើន មានគុណដ៏ច្រើន មានតេជះដ៏ច្រើន មានឫទ្ធិដ៏ច្រើន មានអានុភាពដ៏ច្រើន ។*

**មយ្ហំទីបា មយ្ហំនាថា មយ្ហំបតិដ្ឋា មយ្ហំតាណា មយ្ហំលេណា មយ្ហំបដិសរណា៕** *ព្រះពុទ្ធ ទាំងឡាយនោះ ព្រះអង្គជាទីពឹង ជាទីអាស្រ័យ ជាទីជ្រកកោន ជាទីពួន ជាទីការពារ ជាទីរលឹកនៃយើងខ្ញុំ ។*

**១-អនន្តបុញ្ញា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ បុញ្ញចក្កេហិ មំ រក្ខន្តុ ៕** *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មានបុណ្យដ៏ច្រើន សូមចក្ក គឺបុណ្យដ៏ច្រើន រក្សា នូវខ្ញុំ ។*

**២-អនន្តញាណា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ ញាណចក្កេហិ មំ រក្ខន្តុ ឞ** *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មានញាណដ៏ច្រើន សូមចក្ក គឺញាណដ៏ច្រើន រក្សានូវខ្ញុំ ។*

**៣- អនន្តគុណា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ គុណចក្កេហិ មំ រក្ខន្តុ ឞ** *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មានគុណដ៏ច្រើន សូមចក្កគឺគុណដ៏ច្រើន រក្សានូវខ្ញុំ។*

**៤- អនន្តតេជា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា  អនន្តេហិ តេជចក្កេហិ មំ រក្ខន្តុ ឞ** *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មាន តេជះដ៏ច្រើន សូមចក្ក គឺតេជះដ៏ច្រើន រក្សានូវខ្ញុំ ។*

**៥- អនន្តឥទ្ធិមន្តា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ ឥទ្ធិចក្កេហិ មំ រក្ខន្តុ ឞ** *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មាន ឫទ្ធិដ៏ច្រើន សូមចក្ក គឺឫទ្ធិដ៏ច្រើន រក្សានូវខ្ញុំ ។*

**៦- អនន្តជុតិមន្តា ពុទ្ធា ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធា អនន្តេហិ ជុតិចក្កេហិ មំ រក្ខន្តុ ឞ** *ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ជាព្រះអរហន្ត សម្មាសម្ពុទ្ធ ដែលទ្រង់មាន អានុភាព ដ៏ច្រើន សូមចក្ក គឺអានុភាពដ៏ច្រើន រក្សានូវខ្ញុំ ។*

**ភតា មេ រក្ខា, ភតំ មេ បរិត្តំ, បដិក្កមន្តុ ភូតានិ, សោហំ នមោ ភគវតោ, នមោ សត្តន្នំ សម្មាសម្ពុទ្ធានំ** *កិរិយារក្សា អាត្មាអញបានធ្វើហើយ ទាំងកិរិយាការពារ អាត្មាអញ ក៏បានធ្វើហើយ ពួកសត្វ (កាច) ទាំងឡាយ ចូរចៀសចេញទៅ អាត្មាអញ (ធ្វើឥឡូវនេះ) នូវកិរិយានមស្ការ ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ (អាត្មាអញធ្វើឥឡូវនេះ) នូវកិរិយានមស្ការ ចំពោះ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ ។*

## នមស្ការព្រះពុទ្ធនាមភៃសជ្យគុរុ

**នមោ ភគវតេ ភៃសជ្យគុរុ**
**វៃទូរ្យប្រភរាជាយ តថាគតាយ**
**អហ៌តេ សម្យកសម្ពុទ្ធាយ តទិយថា**
**ឱម ភៃសជ្យេ ភៃសជ្យេ មហាភៃសជ្យ**
**សមុទ្គតេ ស្វាហា ។**

*សូមឲ្យសព្វសត្វបានសម្រេចនូវជោគជ័យ! ខ្ញុំសូមនមស្ការនូវ*
*ព្រះដ៏មានព្រះភាគ ដែលជាភៃសជ្យគុរុ ដូចជាស្តេចនៃពន្លឺកែវ*
*ពិទូរ្យ ជាព្រះតថាគតដែលទ្រង់មានដំណើរល្អយាងទៅកាន់*
*សុន្ទរស្ថាន គឺព្រះនិព្វាន ជាព្រះអរហន្ត ដែលទ្រង់ត្រាស់ដឹងនូវ*

*សម្មាសម្ពោធិញ្ញាណដោយប្រពៃចំពោះព្រះអង្គឯង*
*គ្មានគ្រូអាចារ្យណាប្រដៅព្រះអង្គ*
*ឱម ព្រះអង្គជាគ្រូពេទ្យ ជាគ្រូពេទ្យ ជាកំពូលគ្រូពេទ្យ*
*ជាស្តេចនៃគ្រូពេទ្យ ។*

## ធារណបរិត្ត

១.ពុទ្ធានំ ជីវិតស្ស ន សក្កា កេនចិ អន្តរាយោ កាតុំ, តថា មេ ហោតុ, អតីតំសេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ, អនាគតំសេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ, បច្ចុប្បន្នំសេ ពុទ្ធស្ស ភគវតោ អប្បដិហតំ ញាណំ ។

*រីជីវិតរបស់ព្រះពុទ្ធទាំងឡាយ មិនអាចបុគ្គលណាមួយធ្វើឲ្យអន្តរាយបានឡើយ យ៉ាងណា សូមការរស់នៅរបស់ខ្ញុំ ចូរជាយ៉ាងនោះចុះ, រីព្រះញាណដែលមិនមានគ្រឿងរារាំងរបស់ព្រះពុទ្ធអ្នកមានបុណ្យ រមែង មានក្នុង អតីតៈ ក្នុងអនាគត និងបច្ចុប្បន្ន ។*

២.ឥមេហិ តីហិ ធម្មេហិ សមន្នាគតស្ស ពុទ្ធស្ស ភគវតោ, សព្វំ កាយកម្មំ ញាណបុព្វង្គមំ ញាណានុបរិវត្តិ, សព្វំ វចីកម្មំ ញាណបុព្វង្គមំ ញាណានុបរិវត្តិ, សព្វំ មនោកម្មំ ញាណបុព្វង្គមំ ញាណានុបរិវត្តិ ។

*រីកាយកម្មទាំងពួង របស់ព្រះដ៏មានព្រះភាគដែលជាព្រះពុទ្ធ ប្រកបព្រមដោយគុណធម៌ទាំងនេះ មានញាណជាប្រធាន ប្រព្រឹត្តទៅតាមញាណ រីវចីកម្មទាំងពួងរបស់ព្រះដ៏មានព្រះភាគដែលជាព្រះពុទ្ធ ប្រកបព្រមដោយគុណធម៌ទាំងនេះ មានញាណជាប្រធាន ប្រព្រឹត្តទៅតាមញាណ រីមនោកម្ម ទាំងពួងរបស់ព្រះដ៏មានព្រះភាគដែលជាព្រះពុទ្ធ ប្រកបព្រមដោយគុណធម៌ទាំងនេះ មានញាណជាប្រធាន ប្រព្រឹត្តទៅតាមញាណ ។*

៣.ឥមេហិ ឆហិ ធម្មេហិ សមន្នាគតស្ស ពុទ្ធស្ស ភគវតោ, នត្ថិ ឆន្ទស្ស ហានិ, នត្ថិ ធម្មទេសនាយ ហានិ, នត្ថិ វីរិយស្ស ហានិ, នត្ថិ សមាធិស្ស ហានិ, នត្ថិ បញ្ញាយ ហានិ, នត្ថិ វិមុត្តិយា ហានិ ។

*រីសេចក្តីវិនាសដោយគុណធម៌ ៦ ប្រការទាំងនេះ រមែងមិនមានដល់ ព្រះដ៏មានព្រះភាគ ដែលជាព្រះពុទ្ធ ដែលព្រះអង្គជាអ្នកដល់ព្រមហើយ ពោលគឺ សេចក្តីវិនាស*

ឆន្ទៈ វិនាសដោយការសម្ដែងព្រះធម៌ វិនាសដោយសេចក្ដីព្យាយាម វិនាសដោយសមាធិ វិនាសដោយបញ្ញា និងវិនាសដោយវិមុត្តិញាណ ។

៤.ឥមេហិ ទ្វាទសហិ ធម្មេហិ សមន្នាគតស្ស ពុទ្ធស្ស ភគវតោ, នត្ថិ ទវា, នត្ថិ រវា, នត្ថិ អប្ផុដំ, នត្ថិ វេគាយិតត្តំ, នត្ថិ អព្យាវដមនោ, នត្ថិ អប្បដិសង្ខានុបេក្ខា ។

គុណធម៌ ១២ ប្រការនេះ រមែងមិនមានដល់ព្រះដ៏មានព្រះភាគ ដែលជាព្រះពុទ្ធអ្នកមានបុណ្យ ពោលគឺ ការនិយាយលេង ការនិយាយ ភ្ញាំងភ្ញាត់ ដោយមិនមានសតិ ការមិនផ្សព្វផ្សាយក្នុងញេយ្យធម៌៥ ការ ធ្វើអ្វីនីមួយៗ ដោយមិនមានការពិចារណាមុន សេចក្ដីរវើរវាយដោយ កិលេស និងការធ្វើដែលមិនមានឧបេក្ខាក្នុងតេភូមិកសង្ខារ ។

៥.ឥមេហិ អដ្ឋារសហិ ធម្មេហិ សមន្នាគតស្ស ពុទ្ធស្ស ភគវតោ នមោ សត្តន្នំ សម្មាសម្ពុទ្ធានំ, នត្ថិ តថាគតស្ស កាយទុច្ចរិតំ, នត្ថិ តថាគតស្ស វចីទុច្ចរិតំ, នត្ថិ តថាគតស្ស មនោទុច្ចរិតំ, នត្ថិ អតីតំសេ ពុទ្ធស្ស ភគវតោ បដិហតំ ញាណំ, នត្ថិ អនាគតំសេ ពុទ្ធស្ស ភគវតោ បដិហតំ ញាណំ, នត្ថិ បច្ចុប្បន្នំសេ ពុទ្ធស្ស ភគវតោ បដិហតំ ញាណំ, នត្ថិ សព្វំ កាយកម្មំ ញាណាបុព្វង្គមំ ញាណានុបរិវត្តិ, នត្ថិ សព្វំ វចីកម្មំ ញាណាបុព្វង្គមំ ញាណានុបរិវត្តិ, នត្ថិ សព្វំ មនោកម្មំ ញាណាបុព្វង្គមំ ញាណានុបរិវត្តិ, ឥមំ ធារណំ អមិតំ អសមំ សព្វសត្តានំ តាណំ លេណំ សំសារភយភីតានំ អគ្គំ មហាតេជំ ។

កិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគ ដែលជាព្រះពុទ្ធអ្នកមានបុណ្យទាំង ៧ ព្រះអង្គ ប្រកបដោយគុណ ធម៌ ១៨ ប្រការ, កាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត រមែងមិនមានដល់ ព្រះតថាគត, ញាណដែលមានគ្រឿងរារាំងរបស់ព្រះដ៏មានព្រះភាគ ដែលជាព្រះពុទ្ធអ្នកមានបុណ្យ រមែងមិនមានក្នុងអតីតៈ ក្នុងអនាគត និង ក្នុងបច្ចុប្បន្ន, កាយកម្មទាំងពួង វចីកម្មទាំងពួង និងមនោកម្មទាំងពួង មិនមានញាណជាប្រធាន មិនប្រព្រឹត្តទៅតាមញាណ រមែងមិនមានដល់ ព្រះដ៏មានព្រះភាគឡើយ, ធារណបរិត្តនេះ មិនមានគ្រឿងរារាំង មិនមាន អ្វីស្មើដូច ជាទីជ្រក ជាទីការពាររបស់សត្វអ្នក មានភ័យក្នុងសង្សារវដ្ដ ជាពុទ្ធមន្តដ៏ប្រសើរ មានតេជានុភាពច្រើន ។

៦.ឥមំ អានន្ទ ធារណាបរិត្តំ ធារេហិ វាចេហិ បរិបុច្ឆាហិ, តស្ស កាយេ វិសំ ន កមេយ្យ, ឧទកេ ន លគ្គេយ្យ, អគ្គិ ន ឌហេយ្យ, នានាភយរិកោ, ន ឯកាហារកោ ន ទ្វិហារកោ ន តិហារកោ ន ចតុហារកោ, ន ឧម្មត្តកំ, ន មុឡ្ហកំ, មនុស្សេហិ, អមនុស្សេហិ ន ហឹសកា ។

*ម្នាលអានន្ទ អ្នកចូរទ្រទ្រង់ចាំ សាកសួរនូវធារណបរិត្តនេះ កាយរបស់បុគ្គលអ្នកស្វាធ្យាយមន្តធារណបរិត្តនេះ មិនគប្បីស្លាប់ដោយពិសពស់ ពិសនាគ មិនគប្បីស្លាប់ក្នុងទឹក មិនមានភ្លើងឆេះ ជាបុគ្គលផុតចាក ភ័យវិបត្តិផ្សេងៗ អ្នកណាៗ គិតធ្វើអំពើអាក្រក់ក្នុងមួយថ្ងៃ ពីរថ្ងៃ បីថ្ងៃ បួនថ្ងៃ ឬ ច្រើនថ្ងៃ ក៏មិនអាចសម្រេច មិនមានជំងឺវិកលចរិត មិនឆ្កួត វង្វេង មនុស្សទាំងឡាយ អមនុស្សទាំងឡាយ មិនអាចបៀតបៀនបាន ។*

៧. តំ ធារណំ បរិត្តំ យថា កាតមេ, ជាលោ មហាជាលោ ជាលិត្តេ មហាជាលិត្តេ បុគ្គេ មហាបុគ្គេ សម្បត្តេ មហាសម្បត្តេ ភូតំ គម្ភិ តមង្គលំ។

*ធារណបរិត្តនេះ មានសេចក្តីស័ក្តិសិទ្ធិ គឺមានអានុភាពដូច ព្រះអាទិត្យ ៧ ដួងប្រជុំគ្នា រះឡើងក្នុងវេលាលោកាវិនាស មានអានុភាពដូចចម្រឹងដែក ដែលអាចការពារភ័យពីទេវតា ឥន្ទ នាគ គ្រុឌ យក្ខ ជាដើម មានអានុភាព ប្រហារសត្រូវទាំងឡាយ មានអានុភាពជួយ ឲ្យផុតចាកកប្បទាំង ៣ គឺ រោគន្តរកប្ប សត្ថន្តរកប្ប និងទុព្ភិក្ខន្តរកប្ប មានអានុភាពឲ្យផុតចាករោគផ្សេងៗ ក្នុងវេលាបដិសន្ធិគឺ គប្ធង់ពិការ មិនធ្លាក់ពីដើមឈើ មិនធ្លាក់ក្នុងជ្រោះ មិនធ្លាក់ក្នុងភ្នំស្លាប់ អាចបានសម្បត្តិនៅមិនទាន់បាន ទ្រព្យសម្បត្តិដែលបានហើយ រមែងចម្រើនរុងរឿងឡើង អាចប្រហារភាពងងឹត ហើយមានពន្លឺភ្លឺស្វាង ។*

៨. ឥមំ ខោ បនានន្ទ ធារណាបរិត្តំ សត្តំ សតេហិ សម្មាសម្ពុទ្ធ-កោដីហិ ភាសិតំ, វត្តេ អវត្តេ គន្ធវេ អគន្ធវេ នោមេ អនោមេ សេវេ អសេវេ កាយេ អកាយេ ធារណេ អធារណេ ឥល្ធិ មិល្ធិ តិល្ធិ មិល្ធិ យោរុក្ខេ មហាយោរុក្ខេ ភូតំ គម្ភិ តមង្គលំ ។

*ម្នាលអានន្ទ ធារណបរិត្ត ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយទ្រង់ត្រាស់ទុក គប្បីសមាគមមនុស្សល្អ មិនគប្បីសមាគមមនុស្សអាក្រក់ គប្បីនាំមកនូវក្លិនទិនសដែល*

ជាធម៌ គប្បីនាំមកនូវទឹកចិត្តល្អ មិនគប្បី នាំមកនូវទឹកចិត្តអាក្រក់ គប្បីធ្វើកាយឲ្យជាកាយល្អ គប្បីនាំមកនូវ វត្ថុដែលជាកុសល មិនគប្បីនាំមកនូវវត្ថុដែលជាអកុសល គប្បីស្តាប់ តែវត្ថុដ៏ល្អ គប្បីឃើញតែនិមិត្តដ៏ល្អ មិនគប្បីឃើញនិមិត្តដ៏អាក្រក់ ដើមឈើដែលងាប់អាចធ្វើឲ្យមានសភាពដូចដើម ដើមឈើដែលនៅរស់ ក៏ធ្វើឲ្យដុះចម្រើនឡើង អាចប្រហារធ្មឹត ហើយបាននូវពន្លឺ ។

៩.ឥមំ ខោ បនានន្ទ ធារណាបរិត្តំ នវ ន វុត្តិយា សម្មាសម្ពុទ្ធកោដីហិ ភាសិតំ, ធិដ្ឋិលា ធណ្ឌិលា មន្ទិលា ពេកិលា ខរលា ទុត្តិលា ឯតេន សច្ចវជ្ជេន សោត្ថិ មេ ហោតុ សព្វទា ។

ម្នាលអានន្ទ ធារណបរិត្តនេះ អាចដឹងសេចក្តីគិតអាក្រក់របស់អ្នកដទៃ អាវុធផ្សេងៗ ដែលជាគ្រឿងប្រហារដូច កាំបិត លំពែង កាំភ្លើង ភ្លើង ជាដើម មិនអាចធ្វើអន្តរាយបានឡើយ អាចធ្វើមន្តគាថាឲ្យមានសេចក្តី ស័ក្តិសិទ្ធិឡើង អាចប្រហាររោគផ្សេងៗបាន និងរោគអាក្រក់កាចសាហាវ ផ្សេងៗ មិនអាចធ្វើអន្តរាយបានឡើយ អាចរួចផុតចាកគ្រឿងចំណង ដោយអំណាចនៃសច្ចវាចានេះ សូមសិរីសួស្តីកើតមានដល់ខ្ញុំគ្រប់កាលទៅហោង ។

**គាថាជិនបញ្ជរ**

ជយាសនាគតា ពុទ្ធា ជេត្វា មារំ សវាហិនំ
ចតុសច្ចាមតរសំ បិវឹសុ យេ នរាសភា។

ព្រះពុទ្ធទាំងឡាយអង្គឯណា ជានរាសភៈទ្រង់ជាអ្នក
ដល់ព្រមនូវជ័យជម្នះហើយទ្រង់ឈ្នះនូវមារព្រមទាំង
សេនារបស់មារ ហើយព្រះអង្គទ្រង់សោយនូវទឹក
អម្រឹតគឺអរិយសច្ចៈបួន ។

តណ្ហង្ករាទយោ ពុទ្ធា អដ្ឋវីសតិ នាយកា
សព្វេ បតិដ្ឋិតា មយ្ហំ មត្ថកេ តេ មុនិស្សរា។

ព្រះពុទ្ធទាំងឡាយអង្គនោះ  ជានាយកជាកំពូលនៃអ្នក
ប្រាជ្ញមានម្ភៃប្រាំបីព្រះអង្គមានព្រះពុទ្ធព្រះនាមតណ្ហង្ករ
ជាដើម  សូមព្រះពុទ្ធទាំងឡាយទាំងពួងអង្គនោះ  មក
ប្រតិស្ឋានលើត្បូងគឺក្បាលរបស់ខ្ញុំព្រះអង្គ  ។

**សិរេ  បតិដ្ឋិតោ  ពុទ្ធោ    ធម្មោ ច មម ទ្វិលោចនេ**
**សង្ឃោ បតិដ្ឋិតោ មយ្ហំ    ឧរេ សព្វគុណាករោ ។**

សូមព្រះពុទ្ធមកប្រតិស្ឋានលើសិរសា  សូមព្រះធម៌មកប្រតិស្ឋានត្រង់
កែវភ្នែកទាំងពីរ  សូមព្រះសង្ឃមកប្រតិស្ឋានលើទ្រូងរបស់ខ្ញុំ  ។

**ហទយេ  អនុរុទ្ធោ  ច    សារិបុត្តោ ច ទក្ខិណេ**
**កោណ្ឌញ្ញោ បិដ្ឋិភាគស្មឹ    មោគ្គល្លានោ ច វាមកេ ។**

សូមព្រះអនុរុទ្ធមកប្រតិស្ឋានត្រង់ហឫទ័យរបស់ខ្ញុំ  ព្រះសារីបុត្រសូម
ប្រតិស្ឋានលើស្មាស្តាំ ព្រះកោណ្ឌញ្ញៈ សូមប្រតិស្ឋានខាងខ្នង
ព្រះមោគ្គល្លានសូមប្រតិស្ឋានលើស្មាខាងឆ្វេងរបស់ខ្ញុំ  ។

**ទក្ខិណេ សវនេ មយ្ហំ    អាសុំ  អានន្ទរាហុលា**
**កស្សបោ ច មហានាមោ    ឧភោសុំ  វាមសោតកេ ។**

ព្រះអានន្ទនិងព្រះរាហុលសូមមកប្រតិស្ឋានត្រង់ត្រចៀកស្តាំ  ព្រះកស្សបៈ
និងព្រះមហានាមសូមមកប្រតិស្ឋានត្រង់ត្រចៀកឆ្វេង  ។

**កេសន្តេ  បិដ្ឋិភាគស្មឹ    សុរិយោវ បភង្ករោ**
**និសិន្នោ  សិរិសម្បន្នោ    សោភិតោ  មុនិបុង្គវោ ។**

ព្រះសោភិតៈអ្នករុងរឿងដូចព្រះអាទិត្យ  ដល់ព្រមដោយសិរី  ជាមុនីដ៏ប្រសើរ
សូមមកប្រតិស្ឋានត្រង់ចុងសក់  ។

កុមារកស្សបោ ថេរោ　　　មហេសី ចិត្រវាចកោ
សោ មយ្ហំ វទនេ និច្ចំ　　　បតិដ្ឋាសិ គុណាករោ។

ព្រះកុមារកស្សបត្ថេរជាអ្នកស្វែងរកនូវគុណដ៏ធំ ជាអ្នកមានវាចាពីរោះ ជាអ្នកធ្វើនូវសេចក្តីល្អ សូមមកប្រតិស្ឋានត្រង់មាត់ខ្ញុំជានិច្ច ។

បុណ្ណោ អង្គុលិមាលោ ច　　　ឧបាលិ នន្ទសីវលិ
ថេរា បញ្ច ឥមេ ជាតា　　　នលាដេ តិលកា វិយ។

ព្រះថេរៈទាំងប្រាំព្រះអង្គគឺ ព្រះបុណ្ណៈ ព្រះអង្គុលិមាល ព្រះឧបាលិ ព្រះនន្ទ និងព្រះសីវលី សូមមកប្រតិស្ឋានត្រង់លលាដ៍របស់ខ្ញុំ ។

សេសាសីតិ មហាថេរា　　　វិជិតា ជិនសាវកា
ជលន្តា សីលតេជេន　　　អង្គមង្គេសុ សណ្ឋិតា។

ព្រះថេរៈទាំងឡាយប៉ែតសិបព្រះអង្គដ៏សេស ជាអ្នកឈ្នះកិលេស ជាសាវករបស់ព្រះជិនស្រី រុងរឿងដោយតេជះនៃសីល សូមមកប្រតិស្ឋានត្រង់អវយវៈតូចនិងអវយវៈធំរបស់ខ្ញុំ ។

រតនំ បុរតោ អាសិ　　　ទក្ខិណេ មេត្តសុត្តកំ
ធជគ្គំ បច្ឆតោ អាសិ　　　វាមេ អង្គុលិមាលកំ។

សូមអារាធនារតនបរិត្តមករក្សាពីខាងមុខ មេត្តបរិត្តមករក្សាពីខាងស្តាំ ធជគ្គបរិត្តមករក្សាពីខាងក្រោយ អង្គុលិមាលបរិត្តមករក្សាពីខាងឆ្វេង ។

ខន្ធមោរបរិត្តញ្ច　　　អាដានាដិយសុត្តកំ
អាកាសេ ឆទនំ អាសិ　　　សេសា បាការសណ្ឋិតា។

សូមអារាធនាខន្ធបរិត្ត មោរបរិត្ត និង អាដានាដិយបរិត្តជាគ្រឿងក្រោះបាំងកណ្តាលអាកាស ព្រះបរិត្តដទៃជារនាំងបាំងដោយជុំវិញ ។

ជិនានំ ពលសំយុត្តេ    ធម្មាបាការលង្កតេ

វសតោ មេ សកិច្ចេន    សទា សម្ពុទ្ធបញ្ជរេ ។

វាតបិត្តាទិសញ្ជាតា    ពាហិរជ្ឈត្តុបទ្ទវា

អសេសា វិនយំ យន្តុ    អនន្តជិនតេជសា ។

*កាលខ្ញុំធ្វើនូវកិច្ចរបស់ខ្លួនជាក្រោះកែវរបស់ព្រះសម្ពុទ្ធ ទ្រង់ជាពុទ្ធានុភាព ដែលឡោមព័ទ្ធដោយរនាំងនៃព្រះធម៌ជានិច្ចកាលហើយ សូមអន្តរាយទាំងឡាយ ទាំងខាងក្នុងនិងខាងក្រៅ ដែលកើតអំពីខ្យល់និងប្រមាត់ជាដើម  សូមដល់ នូវសេចក្តីវិនាសបាត់ទៅ  ដោយតេជះនៃព្រះជិនស្រីមិនមានទីបំផុត ៕*

ជិនបញ្ជរមជ្ឈម្ហិ    វិហរន្តំ មហីតលេ

សទា បាលេន្តុ មំ សព្វេ    តេ មហាបុរិសាសភា ។

*សូមព្រះមហាបុរសព្រះអង្គជាអ្នកអង្គអាចគ្រប់ព្រះអង្គ សូមអភិបាលរក្សានូវខ្ញុំដែលជាអ្នកស្ថិតនៅក្នុងជិនបញ្ជរ ដំណើរជីវិតនៅលើផែនដីគ្រប់កាលទៅហោង ៕*

ឥច្ចេវច្ចន្តកតោ សុរក្ខោ

ជិនានុភាវេន ជិតូបទ្ទវោ

ធម្មានុភាវេន ជិតារិសង្ឃោ

សង្ឃានុភាវេន ជិតន្តរាយោ

សទ្ធម្មានុភាវបាលិតោ ចរាមិ ជិនបញ្ជរេ ៕

*ខ្ញុំបានទទួលនូវការរក្សាយ៉ាងល្អ ដោយប្រការយ៉ាងនេះ សូមឲ្យខ្ញុំឈ្នះ នូវឧបទ្រពដោយអានុភាពនៃព្រះជិនស្រី ឈ្នះសឹកសត្រូវដោយអានុភាព នៃព្រះធម៌ ឈ្នះអន្តរាយទាំងឡាយដោយអានុភាពនៃព្រះសង្ឃ, អានុភាពនៃព្រះសទ្ធម្ម សូមគ្រប់គ្រងរក្សាខ្ញុំក្នុងជិនបញ្ជរនេះ ៕*

## មន្តកំពែងព្រះរតនត្រ័យ

*មន្តនេះបានដកស្រង់គាថាធម៌សម្ពុទ្ធេ មកបញ្ចូលគ្នាបង្កើតជាមន្តកំពែងព្រះរតនត្រ័យ ។ ខ្ញុំសូមជូនមន្តនេះមួយដល់ពុទ្ធបរិស័ទដែលមានសទ្ធាចំពោះព្រះរតនត្រ័យ ដើម្បីសូធ្យស្វាធ្យាយនាំមកនូវសិរីសួស្តី បញ្ចៀសភយន្តរាយ ឧបទ្រពផ្សេងៗ ដូចមានកំពែង ៧ ជាន់ការពារខ្លួនយើងជានិច្ច ។ មន្តនេះជាមន្តបុព្វបុរសដែលរក្សាបន្តគ្នាមក ។*

សម្ពុទ្ធេ អដ្ឋវីសញ្ច ពុទ្ធោ មេ អម្ហាកំ ចាការំ ។ ទ្វាទសញ្ច សហស្សកេ ធម្មោ មេ អម្ហាកំ ចាការំ ។ បញ្ចសតសហស្សានិ សង្ឃោ មេ អម្ហាកំ ចាការំ ។ នមាមិ សិរសា អហំ ។ សព្វេ ពុទ្ធា ជនាចិត្តំ, តេសំ ធម្មញ្ច សង្ឃញ្ច សព្វេ ធម្មា ជនាចិត្តំ, អាទរេន នមាមិហំ សព្វេ សង្ឃា ជនាចិត្តំ ។ នមក្ការានុភាវេន មអឌ, ហន្ត្វា សព្វេ ឧបទ្ទវេ ឌអម, អនេកា អន្តរាយាបិ នមោ ពុទ្ធាយ, វិនស្សន្តុ អសេសតោ យទ្ធាពុមោន ។

សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ពុទ្ធោ មេ អម្ហាកំ ចាការំ ។ ចតុវីសតិ-សហស្សកេ ធម្មោ មេ អម្ហាកំ ចាការំ ។ ទសសតសហស្សានិ សង្ឃោ មេ អម្ហាកំ ចាការំ ។ នមាមិ សិរសា អហំ សព្វេ ពុទ្ធា ជនាចិត្តំ ។ តេសំ ធម្មញ្ច សង្ឃញ្ច សព្វេ ធម្មា ជនាចិត្តំ ។ អាទរេន នមាមិហំ សព្វេ សង្ឃា ជនាចិត្តំ ។ នមក្ការានុភាវេន មអឌ, ហន្ត្វា សព្វេ ឧបទ្ទវេ ឌអម, អនេកា អន្តរាយាបិ នមោ ពុទ្ធាយ, វិនស្សន្តុ អសេសតោ យទ្ធាពុមោន ។

សម្ពុទ្ធេ នវុត្តរសតេ ពុទ្ធោ មេ អម្ហាកំ ចាការំ ។ អដ្ឋចត្តាឡីស-សហស្សកេ ធម្មោ មេ អម្ហាកំ ចាការំ ។ វិសតិសតសហស្សានិ សង្ឃោ មេ អម្ហាកំ ចាការំ ។ នមាមិ សិរសា អហំ សព្វេ ពុទ្ធា ជនាចិត្តំ ។ តេសំ ធម្មញ្ច សង្ឃញ្ច សព្វេ ធម្មា ជាជាចិត្តំ ។ អាទរេន នមាមិហំ សព្វេ សង្ឃា ជនាចិត្តំ ។ នមក្ការានុភាវេន មអឌ, ហន្ត្វា សព្វេ ឧបទ្ទវេ ឌអម, អនេកា អន្តរាយាបិ នមោពុទ្ធាយ, វិនស្សន្តុ អសេសតោ យទ្ធាពុមោន ។

## គាថាមហានិព្វមន្ត

**នមោ ពុទ្ធស្ស នមោ ធម្មស្ស នមោ សង្ឃស្ស វិត្តិ វិត្តិ វិត្តិ មិត្តិ មិត្តិ មិត្តិ ចិត្តិ ចិត្តិ វត្តិ វត្តិ មយសុ សុវត្ថិ ហោតុ ហុលូ ហុលូ ហុលូ ស្វាហាយ ។**

*សូមនមស្ការចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាម្ចាស់ ដោយមន្តគាថានេះ សូមសិរីសួស្ដី កើតមានដល់ខ្ញុំព្រះករុណា ។*

**ឥន្ទសាវំ មហាឥន្ទសាវំ ព្រហ្មសាវំ មហាព្រហ្មសាវំ ចក្កវត្តិសាវំ មហាចក្ក~វត្តិសាវំ ទេវាសាវំ មហាទេវាសាវំ ឥសីសាវំ មហាឥសីសាវំ មុនីសាវំ មហាមុនីសាវំ សប្បុរិសសាវំ មហាសប្បុរិសសាវំ ពុទ្ធសាវំ បច្ចេកពុទ្ធសាវំ អរហន្តសាវំ សព្វសិទ្ធិវិជ្ជា~ធារណំសាវំ អរិយានំសាវំ ឯតេន សច្ចេន សុវត្ថិ ហោតុ ។**

*ដោយគាថាមហាទិព្វមន្ត និងដោយការពោលនូវពាក្យសច្ចៈ សូមសិរីសួស្ដី ចូរកើតមានដល់ខ្ញុំព្រះករុណា ។*

**សាវំ គុណំ វជពលំ តេជំ វិរិយំ សិទ្ធិកម្មំ ធម្មំ សច្ចំ និព្វានំ មោក្ខំ គុយ្ហកំ ឧានំ សីលំ បញ្ញានិក្ខំ បុញ្ញំ ភាគ្យំ យសំ តប្បំ សុខំ សិរិរូបំ ចតុវីសតិទេសនំ ឯតេន សច្ចេន សុវត្ថិ ហោតុ ហុលូ ហុលូ ហុលូ ស្វាហាយ ។**

*ដោយមន្តគាថាទាំងនេះ និងដោយការពោលនូវពាក្យសច្ចៈ សូមសិរីសួស្ដី ចូរកើតមានដល់ខ្ញុំព្រះករុណា ។*

## មន្តការពារទាំង ៨ ទិស

សិរស្មឹ មេ ពុទ្ធសេដ្ឋោ　　សារិបុត្តោ ច ទក្ខិណេ
វាមអំសេ មោគ្គល្លានោ　　បុរតោ បិដកត្តយំ។
បច្ឆិមេ មម អានន្ទោ　　ចតុទិសា វីណាសវា
សមន្តា លោកចាលា ច　　ឥន្ទា ទេវា សព្រហ្មកា។
ឯតេសំ អានុភាវេន　　សព្វេ ភយា ឧបទ្ទវា
អនេកា អន្តរាយាបិ　　វិនស្សន្តុ អសេសតោ។

**ប្រែពីបាលីជាកាព្យបុរាណ**

*ព្រះពុទ្ធស្ថិតលើសិរសា　　ព្រះសារីបុត្រណាស្ថិតខាងស្ដាំ*
*ព្រះមោគ្គល្លានឈរប្រចាំ　　ស្ថិតនៅយ៉ាងមាំឯខាងឆ្វេង។*

ព្រះត្រៃបិដកស្ថិតខាងមុខ ជាប្រធានសុខយ៉ាងធំធេង
ព្រះអានន្ទមានឫទ្ធិស្វែង កាន់តំណែងនៅខាងក្រោយ។
ព្រះខីណាស្រពទិសទាំងបួន នៅជុំវិញខ្លួនមួនឥតឆ្ងាយ
ព្រះលោកបាលឥន្ទព្រហ្មអើយនៅការពារជួយទិសប្រាំបី។
អានុភាពនៃអរហន្ត និងទេវត្តឫទ្ធិល្បាញល្បី
អន្តរាយទាំងយប់ទាំងថ្ងៃ សូមវិនាសក្ស័យបាត់ទៅហោង។

## ធាតុចេតិយនមក្ការគាថា

១. មហាគោតមោ ជិនវរោ កុសិនារម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោ។

ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ សារីរិកធាតុ ព្រះមហាគោតម
ដែលទ្រង់និព្វាន ក្រោមសាលព្រឹក្សធំ ជិតបុរីរម្យ ក្រុងកុសិនារា ។
កិរិយាផ្សាយនូវ ព្រះធាតុនានា ផ្សេងៗពីគ្នា ក្នុងទីទាំងឡាយ
ខ្ញុំសូមបង្គំ ប្រណម្យក្រាបថ្វាយ ព្រះធាតុទាំងឡាយ គ្រប់ទីនោះៗ ។

២. ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ
អសម្ភិន្នា ឥមា សត្ត សេសា ភិន្នា វ ធាតុយោ។

ព្រះសារីរិកធាតុ ល្អស្អាតទាំងឡាយ ដែលមិនបែកសោះ ប្រាំពីរព្រះអង្គ
គឺព្រះឧណ្ហី- សធាតុបញ្ចង់[១] មានមួយព្រះអង្គ នៅគង់ល្អស្អាត
និងព្រះទាឋា[២] សារីរិកធាតុ ទាំង៤ អង្គស្អាត គ្មានឃ្លាតបែកចេញ
ព្រះអក្ខកធាតុ[៣] នៅស្អាតពេញលេញ គ្មានបែកបាក់ចេញ ទាំងពីរព្រះអង្គ
ព្រះសារីរិកធាតុ ភ្លឺស្អាតត្រចង់ ប្រាំពីរព្រះអង្គ គង់នៅទាំងអស់
ព្រះសារីរិកធាតុ ដ៏សេសពីនោះ បែកចេញចំពោះ ចំណែកធំតូច ។

៣.មហន្តា មុគ្គមត្តា ច មជ្ឈិមា ភិន្នតណ្ឌុលា

[១] ឆ្អឹងថ្ងាស ២ ព្រះចង្កូមកែវ ៣ ដងកាំបិត ។

**ខុទ្ទកា សាសបមត្តា ច　នានាវណ្ណា ច ធាតុយោ**

ឯព្រះបរមធាតុ មានខ្នាតបីយ៉ាង　លោកបានពោលអាង ទុកជាលំដាប់
ព្រះធាតុខ្នាតធំ ទំហំប៉ុនគ្រាប់　សណ្តែកបាយកាប់ កាត់មួយកំណាត់
ព្រះធាតុកណ្តាល ដូចកាលគេកាត់　ប៉ុនមួយកំណាត់ នៃគ្រាប់អង្ករ
ព្រះធាតុខ្នាតតូច ល្អិតល្អបវរ　លោកបានព្យាករ ថាប៉ុនគ្រាប់ស្ពៃ ។

**៤. មហន្តា សុវណ្ណវណ្ណា ច　មុត្តវណ្ណា ច មជ្ឈិមា**

**ខុទ្ទកា មកុលវណ្ណា ច　សោឡស ទោណមត្តិកា**

ព្រះសារីរិកធាតុ នៃព្រះភគវា　មានពណ៌ផ្សេងគ្នា ទាំងបីវិលាស
ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស　ពន្លឺឱភាស វិសេសពេកក្តាត់ ។
ព្រះធាតុកណ្តាល វិលាសដូចរ័តន៍　មុក្តាប្រាកដ ស្មើរចាប់ប្រឡំ
ព្រះធាតុខ្នាតតូច ដូចផ្កាម្លិះសម　ពណ៌សស្រគាំ ក្រពុំស្រស់ស្អាត
សរុបព្រះធាតុ នៃព្រះសាស្តា　លោកបានពោលថា បើគិតតាមខ្នាត
ដប់ប្រាំមួយនាឡិ មិនបាត់បង់ខាត　បែងចែកជាខ្នាត ចំនួនមួយទោណ ។

**៥. មហន្តា បញ្ច នាឡិយោ　នាឡិយោ បញ្ច មជ្ឈិមា**

**ខុទ្ទកា ច នាឡី ចេវ ឯតា　សព្វាបិ ធាតុយោ ។**

ព្រះបរមធាតុ មុនីនាថសាស្តា　ទាំងអស់នោះណា បែកជាតូចធំ
លោកបានពោលទុក ថាមានទំហំ　មានតូចមានធំ មានខ្នាតកណ្តាល ។
ព្រះធាតុខ្នាតធំ ចំនួនប្រាំនាឡិ　ព្រះធាតុកណ្តាល ប្រាំនាឡិប្រាកដ
ព្រះធាតុខ្នាតតូច ប្រាំមួយនាឡិគត់　តាមលោកកំណត់ បីយ៉ាងដូច្នេះ ។

**៦. អហំ វន្ទាមិ ទូរតោ**

ខ្ញុំសូមលើកហត្ថ ផ្គងនមស្ការ　ព្រះធាតុនោះណា អំពីចម្ងាយ
ឧណ្ហីសាក្ខកធាតុទាំងឡាយ　ប្រណម្យដោយកាយ និងវាចាចិត្ត ។
ព្រះទាឋធាតុ និងធាតុដទៃ　នៃព្រះជិនស្រី ស្ថិតនៅឆ្ងាយជិត
ខ្ញុំសូមនមស្ការ ដោយត្បូងខ្ញុំពិត　ឆ្ពោះព្រះវិជិត-មារនោះហោង ។

# អាការវត្តា

*អាការវត្តា មានន័យថា អាការៈប្រព្រឹត្តទៅនៃព្រះពុទ្ធជាម្ចាស់ ពោលគឺព្រះពុទ្ធគុណ ដែលព្រះអង្គធ្លាប់បានសន្សំមកតាំងពីនៅជាព្រះពោធិសត្វ ឬព្រះពុទ្ធគុណរបស់ព្រះអង្គ ដែលមានយ៉ាងពិតប្រាកដ ។ មានសេចក្តីពោលថា មានទេវបុត្រមួយអង្គ អស់បុណ្យត្រូវច្យុតចាកទេវលោកទៅបដិសន្ធិក្នុងទីដទៃ ។ ទេវបុត្រអង្គនោះ មានសេចក្តីទុក្ខក្រៀមក្រំ មិនចង់ឃ្លាតចាកអត្តភាពនោះ ក៏សាកសួរដល់ពួកទេវបុត្រដទៃទៀត ។ ពួកទេវបុត្រទាំងនោះ ក៏ឲ្យទេវបុត្រអង្គនោះ ស្វាធ្យាយអាការវត្តានេះ ក៏មានបុណ្យកុសលរស់បន្តទៅទៀត ។ បោរាណាចារ្យប្រាប់ថា អ្នកណាសូធ្យធម៌នេះ ត្រឹមមួយដង អាចការពារកយន្តរាយបាន ៣០ មុខ រហូតដល់ទៅ ៤ ខែ ។ ពុទ្ធសាសនិកខ្មែរយើង តែងយកធម៌នេះមកសូធ្យឲ្យអ្នកមានជំងឺធ្ងន់ស្តាប់ ។ អ្នកជំងឺធ្ងន់ខ្លះស្តាប់ហើយ ក៏ជាសះស្បើយពីជំងឺក៏មាន ។*

*បុគ្គលណា ជាសម្មាទិដ្ឋិបុគ្គល បានស្វាធ្យាយធម៌នេះ ជាប្រចាំរមែងជួបសេចក្តីសុខ សិរីសួស្តីក្នុងបច្ចុប្បន្ន គ្មានអន្តរាយណាមួយកើតមានឡើយ ។ បុគ្គលអ្នកស្វាធ្យាយធម៌នេះ នឹងបានជាឧបនិស្ស័យសម្រេចមគ្គផល មិនខានឡើយ ។ សូម្បីប្រាថ្នាក្នុងសម្បត្តិណាមួយ ក៏តែងតែសម្រេចដូចបំណង ។ បើអាការវត្តានេះ មានអានិសង្សយ៉ាងនេះ ! តើអ្នកណាហ្ន៎ នឹងមិនទន្ទេញស្វាធ្យាយ?*

## អាការវត្តា

*អាការៈប្រព្រឹត្តទៅនៃព្រះពុទ្ធជាម្ចាស់*

១. ឥតិបិ សោ ភគវា អរហំ

ឥតិបិ សោ ភគវា សម្មាសម្ពុទ្ធោ

ឥតិបិ សោ ភគវា វិជ្ជាចរណសម្បន្នោ

ឥតិបិ សោ ភគវា សុគតោ

ឥតិបិ សោ ភគវា លោកវិទូ

ឥតិបិ សោ ភគវា អនុត្តរោ បុរិសទម្មសារថិ

ឥតិបិ សោ ភគវា សត្ថា ទេវមនុស្សានំ

ឥតិបិ សោ ភគវា ពុទ្ធោ

ឥតិបិ សោ ភគវា ភគវាតិ

ពុទ្ធគុណវគ្គោ បឋមោ ៗ

២. ឥតិបិ សោ ភគវា អភិនិហារបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឧឡារជ្ឈាសយបារមិសម្បន្នោ

ឥតិបិ សោ ភគវា បណិធានបារមិសម្បន្នោ

ឥតិបិ សោ ភគវា មហាករុណាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា បយោគបារមិសម្បន្នោ

ឥតិបិ សោ ភគវា យុត្តិបារមិសម្បន្នោ

ឥតិបិ សោ ភគវា ជុតិបារមិសម្បន្នោ

ឥតិបិ សោ ភគវា គព្ភឱក្កន្តិបារមិសម្បន្នោ

ឥតិបិ សោ ភគវា គព្ភឋិតិបារមិសម្បន្នោ

អភិនិហារវគ្គោ ទុតិយោ ២

៣. ឥតិបិ សោ ភគវា គព្ភវុដ្ឋានបារមិសម្បន្នោ

ឥតិបិ សោ ភគវា គព្ភមលវិរហិតបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឧត្តមជាតិបារមិសម្បន្នោ

ឥតិបិ សោ ភគវា គតិបារមិសម្បន្នោ

ឥតិបិ សោ ភគវា អភិរូបបារមិសម្បន្នោ

ឥតិបិ សោ ភគវា សុវណ្ណបារមិសម្បន្នោ

ឥតិបិ សោ ភគវា មហាសិរិបារមិសម្បន្នោ

ឥតិបិ សោ ភគវា អារោហបារមិសម្បន្នោ

ឥតិបិ សោ ភគវា បរិណាហបារមិសម្បន្នោ

ឥតិបិ សោ ភគវា សុនិដ្ឋបារមិសម្បន្នោ

គព្ភវុដ្ឋានវគ្គោ តតិយោ ២

៤. ឥតិបិ សោ ភគវា អភិសម្ពោធិបារមិសម្បន្នោ

ឥតិបិ សោ ភគវា សីលក្ខន្ធបារមិសម្បន្នោ

ឥតិបិ សោ ភគវា សមាធិក្ខន្ធបារមិសម្បន្នោ

ឥតិបិ សោ ភគវា បញ្ញាខន្ធបារមិសម្បន្នោ

ឥតិបិ សោ ភគវា ទ្វត្តឹសមហាបុរិសលក្ខណបារមិសម្បន្នោ

អភិសម្ពោធិវគ្គោ ចតុត្ថោ ៗ

៥. ឥតិបិ សោ ភគវា មហាបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា បុថុបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ហាសបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ជវនបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា តិក្ខបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា និព្វេធិកបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា បញ្ចចក្ខុបារមិសម្បន្នោ

ឥតិបិ សោ ភគវា អដ្ឋារសពុទ្ធករបារមិសម្បន្នោ

មហាបញ្ញាវគ្គោ បញ្ចមោ ៗ

៦. ឥតិបិ សោ ភគវា ទានបារមិសម្បន្នោ

ឥតិបិ សោ ភគវា សីលបារមិសម្បន្នោ

ឥតិបិ សោ ភគវា នេក្ខម្មបារមិសម្បន្នោ

ឥតិបិ សោ ភគវា បញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា វីរិយបារមិសម្បន្នោ

ឥតិបិ សោ ភគវា ខន្តិបារមិសម្បន្នោ

ឥតិបិ សោ ភគវា សច្ចបារមិសម្បន្នោ

ឥតិបិ សោ ភគវា អធិដ្ឋានបារមិសម្បន្នោ

ឥតិបិ សោ ភគវា មេត្តាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឧបេក្ខាបារមិសម្បន្នោ

បារមិវគ្គោ ឆដ្ឋោ ៦

៧. ឥតិបិ សោ ភគវា ទសបារមិសម្បន្នោ

ឥតិបិ សោ ភគវា ទសឧបបារមិសម្បន្នោ

ឥតិបិ សោ ភគវា ទសបរមត្ថបារមិសម្បន្នោ

ឥតិបិ សោ ភគវា សមត្តឹសបារមិសម្បន្នោ

ឥតិបិ សោ ភគវា តំ តំ ឈានឈានង្គបារមិសម្បន្នោ

ឥតិបិ សោ ភគវា អភិញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា សតិបារមិសម្បន្នោ

ឥតិបិ សោ ភគវា សមាធិបារមិសម្បន្នោ

ឥតិបិ សោ ភគវា វិមុត្តិបារមិសម្បន្នោ

ឥតិបិ សោ ភគវា វិមុត្តិញាណបារមិសម្បន្នោ

ទសបារមិវគ្គោ សត្តមោ ។

៨. ឥតិបិ សោ ភគវា វិជ្ជាចរណបារមិសម្បន្នោ

ឥតិបិ សោ ភគវា វិបស្សនាវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា មនោមយិទ្ធិវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឥទ្ធិវិធិវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ទិព្វសោតវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា បរចិត្តវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា បុព្វេនិវាសានុស្សតិវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ទិព្វចក្ខុវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា អាសវក្ខយវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ចរណវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ចរណធម្មវិជ្ជាបារមិសម្បន្នោ

ឥតិបិ សោ ភគវា អនុបុព្វវិហារបារមិសម្បន្នោ

វិជ្ជាវគ្គោ អដ្ឋមោ ។

៩. ឥតិបិ សោ ភគវា បរិញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា បហានបារមិសម្បន្នោ

ឥតិបិ សោ ភគវា សច្ឆិកិរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ភាវនាបារមិសម្បន្នោ

ឥតិបិ សោ ភគវា បរិញ្ញាបហានសច្ឆិកិរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ចតុធម្មសច្ចបារមិសម្បន្នោ

ឥតិបិ សោ ភគវា បដិសម្ភិទាញាណបារមិសម្បន្នោ

បរិញ្ញាវគ្គោ នវមោ �9

១០. ឥតិបិ សោ ភគវា ពោធិបក្ខិយធម្មបារមិសម្បន្នោ

ឥតិបិ សោ ភគវា សតិប្បដ្ឋានបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា សម្មប្បធានបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឥទ្ធិបាទបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឥន្ទ្រិយបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ពលបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ពោជ្ឈង្គបញ្ញាបារមិសម្បន្នោ

ឥតិបិ សោ ភគវា អដ្ឋង្គិកមគ្គធម្មបារមិសម្បន្នោ

ឥតិបិ សោ ភគវា មហាបុរិសសច្ឆិកិរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា អនាវរណវិមោក្ខបារមិសម្បន្នោ

ឥតិបិ សោ ភគវា អរហត្តផលវិមុត្តិបារមិសម្បន្នោ

ពោធិបក្ខិយធម្មវគ្គោ ទសមោ ៗ

១១. ឥតិបិ សោ ភគវា ទសពលញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឋានាឋានញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា វិបាកញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា សព្វត្ថគាមិនីបដិបទាញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា នានាធាតុញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា សត្តានំ នានាធិមុត្តិកញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឥន្ទ្រិយបរោបរិយត្តិញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា និរោធឧដ្ឋានញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឈានាទិសង្កិលេសាទិញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា បុព្វេនិវាសានុស្សតិញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ចុតូបបាតញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា អាសវក្ខយញ្ញាណបារមិសម្បន្នោ

ទសពលញ្ញាណវគ្គោ ឯកាទសមោ ៗ

១២. ឥតិបិ សោ ភគវា កោដិសហស្សានំ បកោដិសហស្សានំ ហត្ថីនំ ពលធរបារមិសម្បន្នោ

ឥតិបិ សោ ភគវា បុរិសកោដិទសសហស្សានំ ពលធរបារមិ-
សម្បន្នោ

ឥតិបិ សោ ភគវា បញ្ចចក្ខុញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា យមកញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា សីលគុណបារមិសម្បន្នោ

ឥតិបិ សោ ភគវា គុណបារមិសមាបត្តិបារមិសម្បន្នោ

ឥតិបិ សោ ភគវា បញ្ញាគុណបារមិសម្បន្នោ

កាយពលវគ្គោ ទ្វាទសមោ ១២

១៣.ឥតិបិ សោ ភគវា ថាមពលបារមិសម្បន្នោ

ឥតិបិ សោ ភគវា ថាមពលញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ពលបារមិសម្បន្នោ

ឥតិបិ សោ ភគវា ពលញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា បុរិសបារមិសម្បន្នោ

ឥតិបិ សោ ភគវា បុរិសញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា អតុល្យបារមិសម្បន្នោ

ឥតិបិ សោ ភគវា ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ឧស្សាហបារមិសម្បន្នោ

ឥតិបិ សោ ភគវា គវេសិញ្ញាណបារមិសម្បន្នោ

ថាមពលវគ្គោ តេរសមោ ៗ

១៤.ឥតិបិ សោ ភគវា ចរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ចរិយាញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា លោកត្ថចរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា លោកត្ថចរិយាញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ញាតត្ថចរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ញាតត្ថចរិយាញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ពុទ្ធចរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា ពុទ្ធចរិយាញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា តិវិធចរិយាបារមិសម្បន្នោ

ឥតិបិ សោ ភគវា បារមិឧបបារមិបរមត្ថបារមិសម្បន្នោ

ចរិយាវគ្គោ ចតុទ្ទសមោ ៗ

១៥. ឥតិបិ សោ ភគវា បញ្ចុបាទានក្ខន្ធេសុ អនិច្ចលក្ខណបារមិសម្បន្នោ

ឥតិបិ សោ ភគវា បញ្ចុបាទានក្ខន្ធេសុ ទុក្ខលក្ខណបារមិសម្បន្នោ

ឥតិបិ សោ ភគវា បញ្ចុបាទានក្ខន្ធេសុ អនត្តលក្ខណបារមិសម្បន្នោ

ឥតិបិ សោ ភគវា អាយតនេសុ តិលក្ខណញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា អដ្ឋារសធាតូសុ តិលក្ខណញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា វិបរិណាមលក្ខណបារមិសម្បន្នោ

លក្ខណវគ្គោ បញ្ចទសមោ ៕

១៦. ឥតិបិ សោ ភគវា គតដ្ឋានបារមិសម្បន្នោ

ឥតិបិ សោ ភគវា គតដ្ឋានញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា វសិតបារមិសម្បន្នោ

ឥតិបិ សោ ភគវា វសិតញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា សិក្ខាបារមិសម្បន្នោ

ឥតិបិ សោ ភគវា សិក្ខាញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា សំវរបារមិសម្បន្នោ

ឥតិបិ សោ ភគវា សំវរញ្ញាណបារមិសម្បន្នោ

គតដ្ឋានវគ្គោ សោឡសមោ ៕

១៧. ឥតិបិ សោ ភគវា ពុទ្ធបវេណិបារមិសម្បន្នោ

ឥតិបិ សោ ភគវា ពុទ្ធបវេណិញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា យមកបាដិហារិយបារមិសម្បន្នោ

ឥតិបិ សោ ភគវា យមកបាដិហារិយញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ចតុព្រហ្មវិហារបារមិសម្បន្នោ

ឥតិបិ សោ ភគវា អនាវរណញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា អបរិយន្តញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា សព្វញ្ញុតញ្ញាណបារមិសម្បន្នោ

ឥតិបិ សោ ភគវា ចតុវីសតិកោដិសតវជិរញ្ញាណបារមិសម្បន្នោ

បវេណិវគ្គោ សត្តរសមោ ៧

## អាការវត្តា និដ្ឋិតា

## គំពូលគណ្ឋព្រះត្រៃបិដក

**១.ឥតិបិ សោ ភគវា អរហំ ។ល។ សោ ភគវា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺ កិលេស ព្រមទាំងវាសនាគឺ កាយប្បយោគនិងវចីបយោគ មែនព្រោះហេតុ នេះឯង ។*

**ឥតិបិ សោ ភគវា សម្មាសម្ពុទ្ធោ ។ល។ សោ ភគវា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ មែន ព្រោះហេតុនេះឯង ។*

**ឥតិបិ សោ ភគវា វិជ្ជាចរណសម្បន្នោ ។ល។ សោ ភគវា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ មែនព្រោះហេតុនេះឯង ។*

**ឥតិបិ សោ ភគវា សុគតោ ។ល។ សោ ភគវា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គមានដំណើរល្អយាងទៅកាន់ សុន្ទរស្ថានគឺ អមតមហានិព្វាន មែនព្រោះហេតុនេះឯង ។*

**ឥតិបិ សោ ភគវា លោកវិទូ ។ល។ សោ ភគវា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក មែន ព្រោះហេតុនេះឯង ។*

**អរហន្តំ សរណំ គច្ឆាមិ**

ខ្ញុំព្រះករុណា សូមដល់នូវព្រះអរហន្ត ជាទីពឹងទីរលឹក ។

**អរហន្តំ សិរសា នមាមិ ៕**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរហន្ត ដោយសិរសា គឺត្បូងរបស់ខ្ញុំព្រះករុណា ។

**សម្មាសម្ពុទ្ធំ សរណំ គច្ឆាមិ ៕**

ខ្ញុំព្រះករុណា សូមដល់នូវព្រះសម្មាសម្ពុទ្ធ ជាទីពឹងទីរលឹក ។

**សម្មាសម្ពុទ្ធំ សិរសា នមាមិ ៕**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធ ដោយសិរសា គឺត្បូងរបស់ខ្ញុំព្រះករុណា ។

**វិជ្ជាចរណសម្បន្នំ សរណំ គច្ឆាមិ ៕**

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ដែលព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ ជាទីពឹងទីរលឹក ។

**វិជ្ជាចរណសម្បន្នំ សិរសា នមាមិ ៕**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធ ដែលព្រះអង្គបរិបូណ៌ ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ ដោយសិរសាគឺត្បូង របស់ខ្ញុំព្រះករុណា ។

**សុគតំ សរណំ គច្ឆាមិ ៕**

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ដែលព្រះអង្គមានដំណើរល្អយ៉ាង ទៅកាន់សុន្ទរស្ថាន គឺ អមតមហានិព្វាន ជាទីពឹងទីរលឹក ។

**សុគតំ សិរសា នមាមិ ៕**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធ ដែលព្រះអង្គមាន ដំណើរល្អយ៉ាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន ដោយសិរសាគឺ ត្បូង របស់ខ្ញុំព្រះករុណា ។

**លោកវិទុំ សរណំ គច្ឆាមិ ៕**

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ដែលព្រះអង្គជ្រាបច្បាស់នូវត្រៃ លោក ជាទីពឹងទីរលឹក ។

**លោកវិទុំ សិរសា នមាមិ ៕**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធ ដែលព្រះអង្គជ្រាប ច្បាស់នូវត្រៃលោក ដោយសិរសាគឺត្បូងរបស់ខ្ញុំព្រះករុណា ។

**២.ឥតិបិ សោ ភគវា អនុត្តរោ បុរិសទម្មសារថិ ឥតិ សោ ភគវា ៕**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមាន ឧបនិស្ស័យ គួរនឹងទូន្មានបាន ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គល ណាមួយស្មើគ្មាន មែនព្រោះហេតុនេះឯង ។

**ឥតិបិ សោ ភគវា សត្ថា ទេវមនុស្សានំ ឥតិ សោ ភគវា ៕**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ មែនព្រោះហេតុនេះឯង ។

**ឥតិបិ សោ ភគវា ពុទ្ធោ ឞត សោ ភគវា ឲ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយ ញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង មែនព្រោះហេតុនេះឯង ។

**អនុត្តរំ បុរិសទម្មសារថឹ សរណំ គច្ឆាមិ ឲ**

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ដែលព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន ដែលព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាទីពឹងទីរលឹក ។

**អនុត្តរំ បុរិសទម្មសារថឹ សិរសា នមាមិ ឲ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធ ដែលព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន ដែលព្រះអង្គប្រសើរ ដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ដោយសិរសាគឺត្បូងរបស់ ខ្ញុំព្រះករុណា ។

**សត្ថា ទេវមនុស្សានំ សរណំ គច្ឆាមិ ឲ**

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ដែលព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយជាទីពឹងទីរលឹក ។

**សត្ថា ទេវមនុស្សានំ សិរសា នមាមិ ឲ**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធ ដែលព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ដោយសិរសាគឺត្បូងរបស់ខ្ញុំព្រះករុណា ។

**ពុទ្ធំ សរណំ គច្ឆាមិ ។**

ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក

**ពុទ្ធំ សិរសា នមាមិ ។ ឥតិបិ សោ ភគវា ។**

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះពុទ្ធ ដោយសិរសាគឺត្បូងរបស់ខ្ញុំព្រះករុណា ។

**៣.ឥតិបិ សោ ភគវា រូបក្ខន្ធោ អនិច្ចលក្ខណបារមិ ច សម្បុន្នោ។**

ព្រះដ៏មានព្រះភាគអង្គនោះ រូបក្ខន្ធជាអនិច្ចលក្ខណៈ តែបារមីរបស់ព្រះអង្គនោះ ទ្រង់ដល់ព្រមហើយ ។

**ឥតិបិ សោ ភគវា វេទនាខន្ធោ អនិច្ចលក្ខណបារមិ ច សម្បុន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ វេទនាខន្ធជាអនិច្ចលក្ខណៈ តែបារមីរបស់ព្រះអង្គនោះ ទ្រង់ដល់ព្រមហើយ ។

**ឥតិបិ សោ ភគវា សញ្ញាខន្ធោ អនិច្ចលក្ខណបារមិ ច សម្បុន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ សញ្ញាខន្ធជាអនិច្ចលក្ខណៈ តែបារមី របស់ព្រះអង្គនោះ ទ្រង់ដល់ព្រមហើយ ។

**ឥតិបិ សោ ភគវា សង្ខារក្ខន្ធោ អនិច្ចលក្ខណបារមិ ច សម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ សង្ខារក្ខន្ធជាអនិច្ចលក្ខណៈ តែបារមី របស់ព្រះអង្គនោះ ទ្រង់ដល់ព្រមហើយ ។

**ឥតិបិ សោ ភគវា វិញ្ញាណក្ខន្ធោ អនិច្ចលក្ខណបារមិ ច សម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ វិញ្ញាណក្ខន្ធជាអនិច្ចលក្ខណៈ តែបារមី របស់ព្រះអង្គនោះ ទ្រង់ដល់ព្រមហើយ ។

**៤.ឥតិបិ សោ ភគវា បឋវិធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងបឋវីធាតុ។

**ឥតិបិ សោ ភគវា អាបោធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងអាបោធាតុ។

**ឥតិបិ សោ ភគវា វាយោធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងវាយោធាតុ។

**ឥតិបិ សោ ភគវា អាកាសធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងអាកាសធាតុ។

**ឥតិបិ សោ ភគវា វិញ្ញាណធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងវិញ្ញាណធាតុ។

**ឥតិបិ សោ ភគវា ចក្កវាឡធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងចក្កវាឡធាតុ។

**៥.ឥតិបិ សោ ភគវា ចាតុម្មហារាជិកាធាតុសមាធិញ្ញាណ~សម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលជាទីតាំងនៅរបស់ទេវតាជាន់ចាតុម្ម-ហារាជិកា។

**ឥតិបិ សោ ភគវា តាវត្តឹសាធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលជាទីតាំងនៅរបស់ទេវតាជាន់តាវត្តិង្ស។

**ឥតិបិ សោ ភគវា យាមាធាតុសមាធិញ្ញាណសម្បន្នោ ឞ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលជាទីតាំងនៅរបស់ទេវតាជាន់យាមា។

**ឥតិបិ សោ ភគវា តុសិតាធាតុសមាធិញ្ញាណសម្បន្នោ ឞ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលជាទីតាំងនៅរបស់ទេវតាជាន់តុសិត។

**ឥតិបិ សោ ភគវា និម្មានរតិធាតុសមាធិញ្ញាណសម្បន្នោ ឞ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលជាទីតាំងនៅរបស់ទេវតាជាន់និម្មានរតី។

**ឥតិបិ សោ ភគវា បរិនិម្មិតវសវត្តិធាតុសមាធិញ្ញាណសម្បន្នោឞ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិនិង បញ្ញា គឺការដឹងក្នុងធាតុ ដែលជាទីតាំងនៅរបស់ទេវតាជាន់បរិនិម្មិត-វសវត្តី។

**ឥតិបិ សោ ភគវា កាមាវចរធាតុសមាធិញ្ញាណសម្បន្នោ ឞ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងលោកជាន់កាមាវចរៈ។

**ឥតិបិ សោ ភគវា រូបាវចរធាតុសមាធិញ្ញាណសម្បន្នោ ឞ**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងលោកជាន់រូបាវចរៈ។

**ឥតិបិ សោ ភគវា អរូបាវចរធាតុសមាធិញ្ញាណសម្បន្នោ ម**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិនិងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងលោកជាន់អរូបាវចរៈ។*

**ឥតិបិ សោ ភគវា លោកុត្តរធាតុសមាធិញ្ញាណសម្បន្នោ ម**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិនិងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងលោកុត្តរៈ។*

**៦.ឥតិបិ សោ ភគវា បឋមជ្ឈានធាតុសមាធិញ្ញាណសម្បន្នោ ម**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិនិងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈាន។*

**ឥតិបិ សោ ភគវា ទុតិយជ្ឈានធាតុសមាធិញ្ញាណសម្បន្នោ ម**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិនិងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងទុតិយជ្ឈាន។*

**ឥតិបិ សោ ភគវា តតិយជ្ឈានធាតុសមាធិញ្ញាណសម្បន្នោ ម**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិនិងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងតតិយជ្ឈាន។*

**ឥតិបិ សោ ភគវា ចតុត្ថជ្ឈានធាតុសមាធិញ្ញាណសម្បន្នោ ម**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិនិងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន។*

**ឥតិបិ សោ ភគវា បញ្ចមជ្ឈានធាតុសមាធិញ្ញាណសម្បន្នោ ៗ**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងបញ្ចមជ្ឈាន។*

**៧.ឥតិបិ សោ ភគវា អាកាសានញ្ចាយតនធាតុសមាធិញ្ញាណ-សម្បន្នោ ៗ**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងអរូបាវចរភូមិ គឺអាកា-សានញ្ចាយតនៈ។*

**ឥតិបិ សោ ភគវា វិញ្ញាណញ្ចាយតនធាតុសមាធិញ្ញាណ-សម្បន្នោ ៗ**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងអរូបាវចរភូមិ គឺ វិញ្ញាណញ្ចាយតនៈ។*

**ឥតិបិ សោ ភគវា អាកិញ្ចញ្ញាយតនធាតុសមាធិញ្ញាណសម្បន្នោៗ**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធាតុ ដែលប្រព្រឹត្តទៅក្នុងអរូបាវចរភូមិ គឺ អាកិញ្ចញ្ញាយតនៈ។*

**ឥតិបិ សោ ភគវា នេវសញ្ញានាសញ្ញាយតនធាតុសមាធិញ្ញាណ-សម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងជាតុ ដែលប្រព្រឹត្តទៅក្នុងអរូបាវចរភូមិ គឺនេវសញ្ញា-នាសញ្ញាយតនៈ។

**៨.ឥតិបិ សោ ភគវា សោតាបត្តិមគ្គធាតុសមាធិញ្ញាណសម្បន្នោ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺសោតាបត្តិមគ្គ។

**ឥតិបិ សោ ភគវា សោតាបត្តិផលធាតុសមាធិញ្ញាណសម្បន្នោ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺសោតាបត្តិផល។

**ឥតិបិ សោ ភគវា សកទាគាមិមគ្គធាតុសមាធិញ្ញាណសម្បន្នោ ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺសកទាគាមិមគ្គ។

**ឥតិបិ សោ ភគវា សកទាគាមិផលធាតុសមាធិញ្ញាណសម្បន្នោ។**

ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺសកទាគាមិផល។

**ឥតិបិ សោ ភគវា អនាគាមិមគ្គធាតុសមាធិញ្ញាណសម្បន្នោ ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺអនាគាមិមគ្គ។*

**ឥតិបិ សោ ភគវា អនាគាមិផលធាតុសមាធិញ្ញាណសម្បន្នោ ៗ**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺអនាគាមិផល។*

**ឥតិបិ សោ ភគវា អរហត្តមគ្គធាតុសមាធិញ្ញាណសម្បន្នោ ៗ**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺអរហត្តមគ្គ។*

**ឥតិបិ សោ ភគវា អរហត្តផលធាតុសមាធិញ្ញាណសម្បន្នោ ៗ**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គដល់ព្រមហើយដោយសមាធិ និងបញ្ញា គឺការដឹងក្នុងធម៌ ដែលជាធាតុ គឺអរហត្តផល។*

**៩. កុសលា ធម្មា ឥតិបិ សោ ភគវា អរហា យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ ជម្ពូទីបញ្ច ឥស្សរោ កុសលា ធម្មា នមោ ពុទ្ធាយ នមោ ធម្មាយ នមោ សង្ឃាយ បញ្ច ពុទ្ធេ នមាមិហំ អាបាមចុប ទិមសំអំខុ សំវិធាបុកយប ឧបសជសហេ បាសាយសោ ៗ**

*ធម៌ទាំងឡាយ ជាកុសល ខ្ញុំសូមដល់នូវព្រះពុទ្ធជាម្ចាស់ ជាទីពឹងទី រលឹករហូតអស់មួយជីវិត ព្រះដ៏មានព្រះភាគ ព្រះអង្គជាធំនៃជម្ពូទ្វីប ដោយចំណែកនៃកុសល ខ្ញុំសូមនមស្ការព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ*

*ខ្ញុំសូមនមស្ការព្រះពុទ្ធទាំង ៥ ព្រះអង្គ* **អាបាមចុប** *គឺបណ្តូលនៃព្រះវិនយ-បិដក* **ទីមសំអំខុ** *គឺបណ្តូលនៃព្រះសុត្តន្តបិដក* **សំវិធាបុកយប** *គឺបណ្តូលនៃព្រះអភិធម្មបិដក និង* **ឧបសជសហេ ធាសាយសោ** *គឺបាលីមន្តគាថា ។*

**សោសោ សស អអ អអ និ តេជសុនេមភូចនាវិវេ អសំវិសុ-លោបុសពុភ ឥស្វាសុ សុស្វាឥ កុសលា ធម្មា ចិត្តិ វិអត្តិ ។**

*បណ្តូលលោកុត្តរធម៌ គឺមគ្គ ៤ ផល ៤ និព្វាន ១ បណ្តូលទសជាតក៍ បំពេញបារមី ១០ ព្រះពុទ្ធគុណ ៩ បណ្តូលព្រះត្រៃរតនគុណដោយធម៌ជាចំណែកមានន័យវិចិត្រដ៏ពិស្តារ ។*

**ឥតិបិ សោ ភគវា អរហំ អអា យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ សាពោធិបញ្ញ ឥស្សរោ ធម្មា ។**

*ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺ កាយប្បយោគនិងវចីបយោគ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។*

**កុសលា ធម្មា នន្ទវិវន្តោ ឥតិ សម្មាសម្ពុទ្ធោ សុគលានោ យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ ។**

*ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះ ដែលព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥត*

មានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។

**១០. ចាតុម្មហារាជិកាឥស្សរោ កុសលា ធម្មា ឥតិ វិជ្ជាចរណសម្បន្នោ ឱឱ យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ ។**

ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះ ដែលព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ ប្រសើរជាងទេវលោកជាន់ចាតុម្មហាពជិកា ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។

**តាវតិំសាឥស្សរោ កុសលា ធម្មា ឥតិ សុគតោ លោកវិទូ មហាឯឱ យាវជីវំ សរណំ គច្ឆាមិ ។**

ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះ ដែលព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន និងព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ប្រសើរជាងទេវលោកជាន់តាវត្តិង្ស ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។

**យាមាឥស្សរោ កុសលា ធម្មា ព្រហ្មាសន្ត បញ្ច សត្ត សត្តាបារមី អនុត្តរោ យមកខ យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ ។**

ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះប្រសើរជាងទេវលោកជាន់យាមា ដោយបារមីរបស់ព្រះពោធិសត្វទាំង ៥ កំពូល

ជាងសំឡេងរបស់ព្រះព្រហ្ម ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។

**តុសិតាតស្សរោ កុសលា ធម្មា បុយបក បុរិសទម្មសារថិ យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ ។**

ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះ ដែលព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន ប្រសើរជាងទេវលោកជាន់តុសិតៈ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។

**និម្មានរតីតស្សរោ កុសលា ធម្មា ហេតុចោទ សត្ថា ទេវមនុស្សានំ តថា យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ ។**

ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះ ដែលព្រះអង្គជាសាស្តាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ប្រសើរជាងទេវលោកជាន់និម្មានរតី ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។

**បរិនិម្មិតវសវតី តស្សរោ កុសលា ធម្មា សង្ខារក្ខន្ធោ ទុក្ខំ អនិច្ចំ អនត្តា រូបក្ខន្ធោ ពុទ្ធបជ យាវជីវំ ពុទ្ធំ សរណំ គច្ឆាមិ ។**

ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ដឹងច្បាស់នូវសង្ខារក្ខន្ធថា មិនទៀង ជាទុក្ខ ជាអនត្តា ប្រសើរជាង

*ទេវលោកជាន់បរនិម្មិតវសវត្តី ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ។*

**ព្រហ្មាតិស្សរោ កុសលា ធម្មា នត្ថិបច្ចយា ចិនបញ្ញ តគតតា យាវ និព្វានំ សរណំ គច្ឆាមិ ។**

*ដោយធម៌ជាចំណែកកុសលរបស់ព្រះដ៏មានព្រះភាគអង្គនោះប្រសើរ ជាងទេវលោកជាន់ព្រហ្មលោក ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធអង្គនោះ ជាទីពឹងទីរលឹក រហូតអស់មួយជីវិត ដរាបដល់ព្រះនិព្វាន ។*

**១១. នមោ ពុទ្ធស្ស នមោ ធម្មស្ស នមោ សង្ឃស្ស ចិត្តិ ចិត្តិ ចិត្តិ មិត្តិ មិត្តិ មិត្តិ ចិត្តិ ចិត្តិ វត្តិ វត្តិ មយសុ សុវត្ថិ ហោតុ ហុលុ ហុលុ ហុលុ ស្វាហាយ ។**

*សូមនមស្ការចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាម្ចាស់ ដោយមន្តគាថានេះ សូមសិរីសួស្តី កើតមានដល់ខ្ញុំព្រះករុណា ។*

**ឥន្ទសាវំ មហាឥន្ទសាវំ ព្រហ្មសាវំ មហាព្រហ្មសាវំ ចក្កវត្តិ~សាវំ មហាចក្កវត្តិសាវំ ទេវាសាវំ មហាទេវាសាវំ ឥសីសាវំ មហាឥសីសាវំ មុនីសាវំ មហាមុនីសាវំ សប្បុរិសសាវំ មហា~សប្បុរិសសាវំ ពុទ្ធសាវំ បច្ចេកពុទ្ធសាវំ អរហន្តសាវំ សព្វសិទ្ធិ~វិជ្ជាធរណំសាវំ អរិយានំសាវំ ឯតេន សច្ចេន សុវត្ថិ ហោតុ ។**

*ដោយគាថាមហាទិព្វមន្ត និងដោយការពោលនូវពាក្យសច្ចៈ សូមសិរីសួស្តី ចូរកើតមានដល់ខ្ញុំព្រះករុណា ។*

**សារំ គុណំ វជពលំ តេជំ វិរិយំ សិទ្ធិកម្មំ ធម្មំ សច្ចំ និព្វានំ មោក្ខំ គុយ្ហកំ ធានំ សីលំ បញ្ញានិក្ខំ បុញ្ញំ ភាគ្យំ យសំ តប្បំ សុខំ សិរិរូបំ ចតុវីសតិទេសនំ ឯតេន សច្ចេន សុវត្ថិ ហោតុ ហុលូ ហុលូ ហុលូ ស្វាហាយ ។**

*ដោយមន្តគាថាទាំងនេះ និងដោយការពោលនូវពាក្យសច្ចៈ សូមសិរីសួស្តី ចូរកើតមានដល់ខ្ញុំព្រះករុណា ។*

**១២. នមោ ពុទ្ធស្ស ទុក្ខំ អនិច្ចំ អនត្តា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ នមោ ឥតិបិ សោ ភគវា ។**

*សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ សុទ្ធតែមិនទៀង ជាទុក្ខ ជាអនត្តា ខ្ញុំសូមនមស្ការចំពោះព្រះដ៏មានព្រះភាគអង្គនោះ ដែលព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។*

**នមោ ធម្មស្ស ទុក្ខំ អនិច្ចំ អនត្តា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ នមោ ស្វាក្ខាតោ ភគវតា ធម្មោ ។**

*សូមនមស្ការចំពោះព្រះធម៌ជាម្ចាស់ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ សុទ្ធតែមិនទៀង ជាទុក្ខ ជាអនត្តា ខ្ញុំសូមនមស្ការចំពោះព្រះធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ។*

**នមោ សង្ឃស្ស ទុក្ខំ អនិច្ចំ អនត្តា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ នមោ សុបដិបន្នោ ភគវតោ សាវកសង្ឃោ វាហបរិត្តំ ។**

*សូមនមស្ការចំពោះព្រះសង្ឃជាម្ចាស់ រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ សុទ្ធតែមិនទៀង ជាទុក្ខ ជាអនត្តា ខ្ញុំសូមនមស្ការចំពោះព្រះសង្ឃ ជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។*

**នមោ ពុទ្ធាយ មអរុ ទុក្ខំ អនិច្ចំ អនត្តា យាវ តស្ស ហាយោ នោន ឧអម ទុក្ខំ អនិច្ចំ អនត្តា ឧអមអ វន្ទា នមោ ពុទ្ធាយ នអកតិ និសរណ អារបខុទ្ធំ មអរុ ទុក្ខំ អនិច្ចំ អនត្តា ។**

*សូមនមស្ការចំពោះព្រះពុទ្ធជាម្ចាស់ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជរាបណាមានសេចក្តីមិនទៀង សេចក្តីទុក្ខ និងអនត្តា មានជរាបនោះ ធម្មជាតគ្រប់យ៉ាងមានការអស់ទៅនឹងសូន្យទៅជាធម្មតា ខ្ញុំសូមនមស្ការចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាម្ចាស់ ដោយមន្តគាថាទាំងនេះ ។*

**រាជតោ វា ចោរតោ វា មនុស្សតោ វា អមនុស្សតោ វា អគ្គិតោ វា ឧទកតោ វា បិសាចតោ វា ខាណុកតោ វា កណ្ដកតោ វា នក្ខត្តតោ វា ជនបទរោគតោ វា អសទ្ធម្មតោ វា អសន្ទិដ្ឋិតោ វា អសប្បុរិសតោ វា ចណ្ឌហត្ថិអស្សមិគគោណកុក្កុរ~អហិវិច្ឆិកមណិសប្បទីបិអច្ឆតរច្ឆសូករមហឹសយក្ខរក្ខសាទីហិ នានាភយតោ វា នានារោគតោ វា នានាឧបទ្ទវតោ វា អារក្ខំ គណ្ហន្តុ ។**

*សូមសព្វសត្វបានទទួលនូវការគ្រប់គ្រងរក្សាអំពីភ័យផ្សេងៗ អំពីរោគផ្សេងៗ អំពីឧបទ្រពផ្សេងៗ ដែលកើតអំពីព្រះរាជា ចោរ មនុស្ស អមនុស្ស ភ្លើង ទឹក បិសាច ដង្កត់ឈើ បន្លា នក្ខត្តឫក្ស រោគក្នុងជនបទ សេចក្ដីប្រព្រឹត្តរបស់មនុស្សអាក្រក់ ការឃើញខុសរបស់មនុស្សអាក្រក់ ដំរី សេះ ម្រឹគ គោ ឆ្កែ ពស់ ខ្ទួយ ពស់ខៀវ ខ្លាឃ្មុំ ខ្លាដំបង ខ្លារខិន ជ្រូក ក្របី យក្ខ អារក្ខជាដើម ដ៏កាចសាហាវ ។*

## **អសីតិមហាសាវ័ក**

*ព្រះអសីតិមហាសាវ័ក ក្នុងព្រះពុទ្ធសាសនាមានចំនួន ៨០ ព្រះអង្គ ជាអ្នកមានឫទ្ធានុភាពច្រើន មានអភិញ្ញាដ៏ធំក្រៃលែង ដែលព្រះពុទ្ធជាម្ចាស់ទ្រង់លើកតម្កើងជាមហាសាវ័កដ៏ថ្នើម ។ ពួកព្រហ្ម និងទេវតាទាំងឡាយតែងគោរពនមស្ការចំពោះព្រះមហាថេរទាំងឡាយនោះ ។ បុគ្គលណាដែលបាននមស្ការរលឹកដល់ព្រះអសីតិមហាសាវ័កទាំងនោះ ពួកទេវតាទាំងឡាយ នឹងចូលចិត្តស្រឡាញ់អ្នកនោះ ជួយការពារគ្រប់គ្រងឲ្យមានសិរីសួស្តីសព្វកាលវេលា ។ ខាងក្រោមនេះ ជាព្រះនាមព្រះអសីតិមហាសាវ័ក សូមពុទ្ធសាសនិក ទន្ទេញស្វាធ្យាយនឹងនាំមកនូវប្រយោជន៍ដ៏ធំ មិនអាចគណនាបាន ។*

អញ្ញាសិកោណ្ឌញ្ញោ, វប្បោ, ភទ្ទិយោ, មហានាមោ, អស្សជិ, នាលកោ, យសោ, វិមលោ, សុពាហុ, បុណ្ណជិ, គវម្បតិ, ឧរុវេល-កស្សបោ, នទីកស្សបោ, គយាកស្សបោ, សារិបុត្តោ, មហា-មោគ្គល្លានោ, មហាកស្សបោ, មហាកច្ចាយនោ, មហាកោដ្ឋិកោ, មហាកប្បិនោ, មហាចុន្ទោ, អនុរុទ្ធោ, កង្ខារេវតោ, អានន្ទោ, នន្ទកោ, ភគុ, នន្ទោ, កិមិលោ, ភទ្ទិយោ, រាហុលោ, សីវលិ, ឧចាលិ, ទព្វោ, ឧបសេនោ, ខទិរវនិយរេវតោ, បុណ្ណោ មន្តាណិបុត្តោ, បុណ្ណោ សុនាបរន្តកោ, សោណោ កុដិកណ្ណោ, សោណោ កោឡិវិសោ,

ភាទោ, សុភូតិ, អង្គុលិមាលោ, វក្កលិ, កាឡុទាយី, មហាឧទាយី, បិលិន្ទវច្ឆោ, សោភិតោ, កុមារកស្សបោ, រដ្ឋបាលោ, វង្គីសោ, សភិយោ, សេលោ, ឧបវាណោ, មេឃិយោ, សាគតោ, នាគិតោ, លកុណ្ឌកភទ្ទិយោ, បិណ្ឌោលភារទ្វាជោ, មហាបន្ថកោ, ចូឡ-បន្ថកោ, ពាកុលោ, កុណ្ឌធានោ, ទារុចីរិយោ, យសោជោ, អជិតោ, តិស្សមេត្តេយ្យោ, បុណ្ណកោ, មេត្តគូ, ធោតកោ, ឧបសិវោ, នន្ទោ, ហេមកោ, តោទេយ្យោ, កប្បោ, ជតុកណ្ណិ, ភទ្រាវុធោ, ឧទយោ, បោសាលោ, មោឃរាជា, បិង្គិយោតិ ឯតេ អសីតិមហាសាវកា ។

សព្វេ វិជិតសង្គាមា ភយាតីតា យសស្សិនោ
មោទន្តិ សហ ភូតេហិ សាវកា តេ ជនេសុតា ។

*ពួកសាវកទាំងនោះ លោកឈ្នះសឹកសង្គ្រាមហើយ កន្លងបង់នូវសេចក្តីភ័យខ្លាចបានហើយ មានយសល្បីទូរទ័រទៅក្នុងប្រជុំជន តែងរីករាយជាមួយនឹងព្រះអរិយៈដែលកើតហើយក្នុងសាសនានៃព្រះទសពល ។*

វិសុទ្ធា ច មហាថេរា ឧជុចិត្តា និរង្គណា
តេបិ អម្ហេ នុរក្ខន្តុ អរោគេន សុខេន ច ។

*រីឯព្រះមហាថេរទាំងឡាយ ជាអ្នកបរិសុទ្ធ មានចិត្តត្រង់ មិនមានកិលេស សូមព្រះមហាថេរទាំងឡាយនោះ ចូរបីបាច់រក្សានូវខ្ញុំទាំងឡាយ ដោយមិនឲ្យមានរោគផង ឲ្យមានសេចក្តីសុខផង ។*

## ជីវទានគាថា

អត្ថិ ឧណ្ហិស្សវិជយោ ធម្មោ លោកេ អនុត្តរោ
សព្វសត្តហិតត្ថាយ តំ ត្វំ គណ្ហាហិ ទេវតេ ។

*ព្រះធម៌ដែលជាឧណ្ហិស្សវិជ័យដ៏ប្រសើរ តែងមានក្នុង លោក ដើម្បីសេចក្ដីចម្រើនដល់សត្វលោកទាំងពួង ម្នាលទេវតា អ្នកចូររៀនយកនូវព្រះធម៌នោះ ។*

បរិវជ្ជេ រាជចោរេ អមនុស្សេហិ ចាវកេ
ព្យគ្ឃេ នាគេ វិសេ ភូតេ អកាលមរណេន វា ។

*ជាព្រះធម៌រួចផុត ពីរាជ អាជ្ញា ពីអមនុស្សកាចៗ ពីខ្លា ពីនាគ និងសត្វដែលមានពិស ពីសេចក្ដីស្លាប់មិនត្រូវ កាលវេលា ។*

សព្វស្មា មរណា មុត្តោ ឋបេត្វា កាលមារិតំ
តស្សេវ អានុភាវេន ហោតុ ទេវោ សុខី សទា ។

*រមែងរួចផុតពីមរណៈទាំងពួង វៀរលែងតែកាលមរណៈ ចេញ ដោយអានុភាពនៃព្រះធម៌នោះឯង សូមឲ្យទេវតា បាននូវសេចក្ដីសុខគ្រប់កាល ។*

សុទ្ធសីលំ សមាទាយ    ធម្មំ សុចរិតំ ចរេ

តស្សេវ អានុភាវេន    ហោតុ ទេវោ សុខី សទា ។

*កាលសមាទាននូវសីលដ៏បរិសុទ្ធ កាលប្រព្រឹត្តិនូវធម៌*
*ដែលជាសុចរិត ដោយអានុភាពនៃព្រះធម៌នោះឯង*
*សូមឲ្យទេវតាបាននូវសេចក្តីសុខគ្រប់កាល ។*

លិក្ខិតំ ចិន្តិតំ បូជំ    ធារណំ វាចនំ គរុំ

បរេសំ ទេសនំ សុត្វា    តស្ស អាយុ បវឌ្ឍតិ ។

*អាយុតែងចម្រើនដល់បុគ្គលអ្នកកត់ត្រាទុក គិត បូជា*
*ទ្រទ្រង់ចាំ បង្រៀន គោរព ស្តាប់ពីអ្នកដទៃ ។*

សក្កត្វា ពុទ្ធរតនំ    ឱសថំ ឧត្តមំ វរំ

ហិតំ ទេវមនុស្សានំ    ពុទ្ធតេជេន សោត្ថិនា

នស្សន្តុបទ្ទវា សព្វេ    ទុក្ខា វូបសមេន្តុ តេ ។

*សូមឲ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឲ្យសេចក្តី*
*ទុក្ខទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយ*
*តេជានុភាពនៃព្រះពុទ្ធជាម្ចាស់ ព្រោះធ្វើគោរពនូវព្រះពុទ្ធរតន៍ ដូចជា*
*ឱសថដ៏ឧត្តមប្រសើរ ជាប្រយោជន៍ដល់ទេវតានិងមនុស្សទាំងពួង ។*

សក្កត្វា ធម្មរតនំ ឱសថំ ឧត្តមំ វរំ

បរិឡាហូបសមនំ ធម្មតេជេន សោត្ថិនា

នស្សន្តុបទ្ទវា សព្វេ ភយា វូបសមេន្តុ តេ ។

*សូមឲ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឲ្យភ័យ ទាំងឡាយរបស់អ្នកស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយ តេជានុភាពនៃព្រះធម៌ ព្រោះធ្វើគោរពនូវព្រះធម្មរតន៍ ដូចជាឱសថដ៏ ឧត្តមប្រសើរ ជាគ្រឿងរម្ងាប់នូវសេចក្តីក្រវល់ក្រវាយ ។*

សក្កត្វា សង្ឃរតនំ ឱសថំ ឧត្តមំ វរំ

អាហុនេយ្យំ ចាហុនេយ្យំ សង្ឃតេជេន សោត្ថិនា

នស្សន្តុបទ្ទវា សព្វេ រោគា វូបសមេន្តុ តេ ។

*សូមឲ្យឧបទ្រពទាំងឡាយទាំងពួង វិនាសបាត់ទៅ សូមឲ្យរោគ ទាំងឡាយរបស់អ្នក ស្ងប់រម្ងាប់ទៅ ដោយសិរីសួស្តី ដោយ តេជានុភាពនៃព្រះសង្ឃ ព្រោះធ្វើគោរពនូវព្រះសង្ឃរតន៍ ដូចជា ឱសថដ៏ឧត្តមប្រសើរ ជាវត្ថុគួរគេនាំមកបូជា ជាវត្ថុគួរគេទទួល រាក់ទាក់ ។*

**តតោ ពុទ្ធរតនំ អនុស្សរិត្វា អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ** បន្ទាប់មក គប្បីរលឹកដល់ព្រះពុទ្ធរតនៈ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ។

**ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺ កិលេសព្រមទាំងវាសនាគឺ កាយប្បយោគនិងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និង ចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អឃាងទៅកាន់សុន្ទរស្ថានគឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន **បុរិសធម្មសារថិ** ទ្រង់ព្រះនាមថា **បុរិសធម្មសារថិ** ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ**

ទ្រង់ព្រះនាមថា **សត្ថា ទេវមនុស្សានំ** ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវាតិ** ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។ **សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ ។** ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ចំពោះព្រះអង្គ នូវលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចំពោះព្រះអង្គ ទ្រង់ញ៉ាំងនូវពពួកសត្វ ព្រមទាំងសមណៈនិងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ។ **សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ, កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ;** ព្រះអង្គទ្រង់ប្រកាស ទ្រង់សម្តែងធម៌ ពីរោះបទដើម បទកណ្តាល និងបទចុង ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។ **សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតិ** ក៏ដំណើរដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។ **ឯតេន**

សច្ចវជ្ជេន ហោតុ មេ សោត្ថិមង្គលំ សូមសិរីសួស្តីជយមង្គល ចូរមាន ដល់ខ្ញុំព្រះករុណា ដោយកិរិយានូវពោលនូវពាក្យសច្ចៈ ។

តតោ ធម្មរតនំ អនុស្សរិត្វា អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ បន្ទាប់មក គប្បីរលឹកដល់ព្រះធម្មរតនៈ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ស្វាក្ខាតោ ភគវតា ធម្មោ ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការគឺមគ្គ ៤ ផល ៤ និព្វាន ១ ) សន្ទិដ្ឋិកោ ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្ដាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង អកាលិកោ ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ ឯហិបស្សិកោ ជាធម៌គួរដល់ ឯហិបស្សវិធី គឺថាបើ ព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន ឱបនយិកោ ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញ

ច្បាស់ក្នុងចិត្តនៃខ្លួន ។ **ឯតេន សច្ចវជ្ជេន ហោតុ មេ សោត្ថិមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយានូវពោលនូវពាក្យសច្ចៈ ។

**តតោ សង្ឃរតនំ អនុស្សរិត្វា អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ,** បន្ទាប់មក គប្បីរលឹកដល់ព្រះសង្ឃរតនៈ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ។

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រង់គឺ ប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ថានក្សេមផុតចាកទុក្ខទាំងពួង **សាមីចិបដិបន្នោ ភគវតោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូគឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ១ សកទាគាមិមគ្គនិងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១

អរហត្តមគ្គ និងអរហត្តផលជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **ចាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្តដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ** លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ **ឯតេន សច្ចវជ្ជេន ហោតុ មេ សោត្ថិមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយានូវពោលនូវពាក្យសច្ចៈ ។

ភេសជ្ជំ ទេវមនុស្សានំ កដុកំ តិត្តិការសំ
អម្ពិលំ លវណាញ្ចេវ សព្វព្យាធិ វិនស្សតិ ។

*ថ្នាំនៃទេវតានិងមនុស្សទាំងឡាយ មានរសហឹរ មានរសចត់ មានរសជូរ មានរសប្រៃ តែងវិនាសនូវជំងឺទាំងពួង។*

ឯកទ្វិតិទិនំ វាបិ បញ្ចសត្តទិនំ តថា

យាវ ឧក្ខា ន សមេន្តិ ជីវទានំ ករោតុ មេ។

*បើប្រើមួយថ្ងៃ ពីរថ្ងៃ ឬបីថ្ងៃ ឬក៏ប្រាំថ្ងៃ ឬមួយប្រាំមួយថ្ងៃ ឬក៏អាចដល់ ប្រាំពីរថ្ងៃ នៅមិនជាសះស្បើយ សូមធ្វើនូវជីវទាន ដល់ខ្ញុំ ។*

ជីវទានំ ទទន្តស្ស អាយុំ វណ្ណំ សុខំ ពលំ

ជីវទានានុភាវេន ហោតុ ទេវោ សុខី សទា ។

*កាលអ្នកឲ្យនូវជីវទាន គឺឲ្យនូវអាយុ វណ្ណៈ សុខៈ និងពលៈ ដោយអានុភាពនៃជីវទាននេះ សូមឲ្យទេវតាបាននូវសេចក្តីសុខគ្រប់កាល ។*

ជីវទានំបិ ទត្វាន ឱសថំ ឧត្តមំ វរំ

សរីរទុក្ខំ នាសេតិ ភេសជ្ជំ ទានមុត្តមំ ។

*សូម្បីឲ្យនូវជីវទាន ឈ្មោះថា ឲ្យនូវឱសថដ៏ឧត្តមប្រសើរ សេចក្តីទុក្ខក្នុងរាងកាយ ក៏វិនាសបាត់ទៅ ថ្នាំជាទានដ៏ឧត្តម។*

តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ

បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។

*ព្រោះហេតុដូច្នោះហើយ សាធុជនអ្នកមានចំណង់ចង់បានសេចក្តីសុខ (ដល់ខ្លួន) គួរតែប្រញាប់ប្រញាល់ធ្វើអំពើបុណ្យ ដែលជាគុណ គឺអ្នកប្រាជ្ញតែងរាប់អាន ឲ្យបានជានិច្ច គឺខ្លួនត្រូវកសាងសន្សំ (គ្រាន់នឹងបានជាទីពឹង) ទៅក្នុងភពខាងនាយ (ព្រោះថា) បុណ្យទាំងឡាយតែងជាទីពឹងពំនាក់របស់សត្វទាំងឡាយក្នុងបរលោក ។*

**ឥមិនា ជីវទានេន　　　　តុម្ហាកំ កិំ ភវិស្សតិ**

**ទីឃាយុកា សទា ហោន្តិ សុខិតា ហោន្តិ សព្វទា ។**

*ដោយជីវទាននេះ អ្នកនឹងបានអានិសង្សដូចម្តេច នឹងជាអ្នកមានអាយុវែងសព្វកាល នឹងមានសេចក្តីសុខ គ្រប់កាល ។*

**ជីវទានំ ទទន្តស្ស　　　　អាយុំ វណ្ណំ សុខំ ពលំ**

**ទីឃាយុកា សទា ហោន្តុ ជីវទានំ មហាប្ផលំ ។**

*កាលអ្នកឲ្យនូវជីវទាន គឺឲ្យនូវ អាយុ វណ្ណៈ សុខៈ និងពលៈ ចូរអាយុវែងសព្វកាល ជីវទាន មានផលច្រើន ។*

**យោ សោ ទទាតិ សក្កច្ចំ សីលវន្តេសុ តាទិសុ**

**ចាណាទានំ វរំ ទត្វា　　　ជីវទានំ មហាប្ផលំ ។**

*បុគ្គលណាឲ្យនូវជីវិតដ៏ប្រសើរ ក្នុងអ្នកមានសីល បុគ្គលនោះ ឈ្មោះថា ឲ្យដោយគោរព ជីវទាន មានផលច្រើន ។*

ឯវំ មហិទ្ធិកា ឯសា  យទិទំ បុញ្ញសម្បទា
តស្មា ធីរា បសំសន្តិ  បណ្ឌិតា កតបុញ្ញតំ ។

*បុញ្ញសម្បទា គឺគុណជាតិជាហេតុដល់ព្រមគឺបុណ្យឯណា បុញ្ញសម្បទានេះ មានឫទ្ធិដ៏ធំក្រៃលែង ដោយប្រការយ៉ាងនេះ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ អ្នកមានប្រាជ្ញា រមែងសរសើរនូវភាពនៃបុគ្គលអ្នកមានបុណ្យធ្វើទុកហើយ ។*

តេន ពុទ្ធានុភាវេន  តេន ធម្មានុភាវេន
តេន សង្ឃានុភាវេន  សព្វចាចា វិនស្សន្តុ ។

*សូមឲ្យបាបទាំងពួងទាំងឡាយ ចូរវិនាសបាត់ទៅ ដោយអានុភាពនៃព្រះពុទ្ធនោះ ដោយអានុភាពនៃព្រះធម៌នោះ ដោយអានុភាពនៃព្រះសង្ឃនោះ ។*

តេន ទានានុភាវេន  តេន សីលានុភាវេន
តេន សច្ចានុភាវេន  សព្វចាចា វិនស្សន្តុ ។

*សូមឲ្យបាបទាំងពួងទាំងឡាយ ចូរវិនាសបាត់ទៅ ដោយអានុភាពនៃទាននោះ ដោយអានុភាពនៃសីលនោះ ដោយអានុភាពនៃសច្ចៈនោះ ។*

ជីវទានានុភាវេន  សព្វេ ឧបទ្ទវា
ទុក្ខរោគភយា ចាតិ  វិនស្សន្តុ អសេសតោ ។

*ដោយអានុភាពនៃជីវទាន សូមឲ្យឧត្បាតនិងឧបទ្រពទាំងឡាយទាំងពួង សេចក្តីទុក្ខ រោគ និងភ័យ ចូរឲ្យវិនាសបាត់ទៅ កុំបីមានសេសសល់ឡើយ ។*

## មហាមេត្តាធាថ

មេត្តាសុត្តំ រតនញ្ច ខន្ធាដានាដិយំ តថា ធជគ្គំ អង្គុលិមាលញ្ច ធិសាចាលញ្ច សត្តមំ អដ្ឋវីសតិពុទ្ធបរិត្តញ្ច អដ្ឋមង្គលំ ។ *មេត្តាសូត្រ រតនបរិត្ត ខន្ធបរិត្ត អាដានាដិយបរិត្ត ធជគ្គបរិត្ត អង្គុលិមាលបរិត្ត ទិសាបាលបរិត្ត[1] បរិត្តនៃព្រះពុទ្ធម្ភៃប្រាំបីព្រះអង្គ[2] និងពុទ្ធជយមង្គល ៨ ប្រការ[3] ។* សេយ្យថីទំ ។ *តើមានប្រការដូចម្តេចខ្លះ ។* បណ្ណារសាតិ វុត្តំ មារវិជយញ្ច ជយញ្ច ធារណាគិរិមានន្ទមោគ្គល្លានញ្ច ចុន្ទញ្ច កស្សបំ មារាខនុតថាយ ។ សុរិយចន្ទញ្ចេវ ធន្ទុន្តំ វដ្ដជាតកំ មោរមង្គលបរិត្តញ្ច រាហុលញ្ច បរិត្តានិ សិរសានិ ច លោកានញ្ច ហិតត្ថាយ អត្តនោ សាវកា ច មាតាបិតុស្ស *ព្រះបរិត្តទាំង ១៥ គឺ មារវិជយបរិត្ត[4] ជយបរិត្ត ធារណបរិត្ត គិរិមានន្ទបរិត្ត មោគ្គល្លានបរិត្ត*

---

*១ មន្តតតិបិសោ ៨ ទិស ។ ២ ធម៌ នមោ សព្វពុទ្ធានំ ។ ៣ ធម៌ពាហុំ ។ ៤ ប្រហែលបទស្រែកជ័យឃោសអភិសេក។*

ចុន្ទបរិត្ត កស្សបបរិត្ត មារាខនុបរិត្ត[១] សុរិយបរិត្ត ចន្ទិមបរិត្ត ធជគ្គបរិត្ត វដ្តកបរិត្ត មោរបរិត្ត មង្គលបរិត្ត រាហុលបរិត្ត ព្រះបរិត្តដ៏កំពូល ដើម្បីសេចក្តីចម្រើនដល់សត្វលោកផង ដល់សាវ័ករបស់ខ្លួនផង ដល់មាតាបិតាផង **សព្វានិ ចតុវីសានិ ពុទ្ធេនេវ បកាសិតា អត្ថាយ ហិតាយ សុខាយ សព្វលោកស្សាតិ** ព្រះបរិត្តទាំង ២៤ នេះ ដែលព្រះពុទ្ធទ្រង់សម្តែងហើយ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់សត្វលោក។

**ឥមេ មាតាបិតរោ បរលោកំ គន្ត្វា ឥធ សាសនេ ឥមស្ស មាតាបិតុស្ស អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ។**

មាតាបិតាទាំងឡាយ ដែលទៅកាន់បរលោកហើយក្តី ដែលមានជីវិតរស់នៅ ក្នុងសាសនានេះក្តី សូមកុំមានពៀរនឹងគ្នា សូមឲ្យបានទទួលសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។

---

១ ប្រហែលមន្ត ចំណាងព្រះឧបគុត្ត ។

ឥមេ ភគនិយា ញាតកា ពន្ធុវកុលុបកសហាយកា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។

*ញាតិ ដែលជាបងប្អូន ផៅពង្សសន្តាន ជីតុន និងសម្លាញ់ទាំងឡាយ សូមកុំមានពៀរនឹងគ្នា សូមឲ្យបានទូវសេចក្ដីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្ដីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមេ រាជានោ ទេវាធិបតិទេវា សហ បុត្តទារា សហ អមច្ចា សហ បរិវារា ជនា សហ សេនាបតិ សហ ពលពាហនា សហ ទាសាទាសី ហត្ថីអស្សគោណមហឹសាទយោ អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ។

*ព្រះរាជាទាំងឡាយ ទេវាធិបតីទាំងឡាយ មួយអន្លើដោយបុត្រនិងភរិយា មួយអន្លើដោយអាមាត្យ មួយអន្លើដោយជនដែលជាបរិវារ មួយអន្លើដោយសេនាបតី មួយអន្លើដោយពលពាហនៈ មួយអន្លើដោយទាសាទាសី និងដំរី សេះ គោ ក្របីជាដើម សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្ដីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្ដីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

**ឥមស្មឹ គាមេ វា រាជធានិយោ វា អរញ្ញេសុ វា សព្វេសត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហារន្តុ ។**

*សត្វទាំងឡាយទាំងពួង ដែលនៅក្នុងស្រុកក្ដី រាជធានីក្ដី ព្រៃក្ដី សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្ដីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្ដីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

**ឥមេ មនុស្សា ច រត្តិន្ទិវញ្ច ឥត្ថី វា បុរិសោ វា កុមារោ វា កុមារី វា យេ ច ទហរា, យេ ច មជ្ឈិមបុរិសា, យេ ច វុឌ្ឍា,**

យេ ច ទលិទ្ទា, យេ ចសមិទ្ធា, យេ ច ពាលា, យេ ច បណ្ឌិតា, យេ ច សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ,សម្បត្តីហិ សមិជ្ឈន្តុ,សុខី អត្តានំ បរិហរន្តុ ។

*មនុស្សទាំងឡាយនេះ ទោះជាស្ត្រីក្តី បុរសក្តី កុមារាក្តី កុមារីក្តី កម្លោះក្តី អ្នកកណ្តាលក្តី អ្នកមានក្តី អ្នកក្រក្តី អ្នកសម្រេចក្តី ពាលក្តី បណ្ឌិតក្តី ម្យ៉ាងទៀត សត្វទាំងឡាយទាំងពួងឯណា សូមកុំមានពៀរនឹងគ្នា សូមឲ្យបានទូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅទាំងយប់ទាំងថ្ងៃ ។*

អយំ សុរិយោ ច, អយំ ចន្ទោ ច, ពរុណោ ច, នាគោ ច, ភារទ្វាជោ ច, សុមនោ ច, សហទេវា មហិទ្ធិកា មហានុភាវា ច, អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ,សុខី អត្តានំ បរិហរន្តុ។

*សុរិយទេពនេះ ចន្ទទេពនេះ ពរុណទេពនេះ នាគទេពនេះ ភារទ្វាជទេពនេះ សុមនទេពនេះ សហទេពនេះ ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន សូមកុំមានពៀរនឹងគ្នា សូមឲ្យបានទទួលសេចក្ដីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្ដី ព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមេ ចាតុម្មហារាជិកាទេវា តាវត្តឹសាទេវា យាមាទេវា តុសិតាទេវា និម្មានរតិទេវា បរនិម្មិតវសវត្តិទេវា យាវ ព្រហ្មលោកា ព្រហ្មចារិសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណ-សុភា សុភាកិណ្ហកា វេហប្ផលា អសញ្ញីសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋកា អាកាសានញ្ចាយតនំ វិញ្ញា-ណញ្ចាយតនំ អាកិញ្ចញ្ញាយតនំ នេវសញ្ញានាសញ្ញាយតនំ មហាព្រហ្មសង្ខាតា បឋវិតលតោ យាវ ភវគ្គសមន្តតោ ច អវិជ្ជហិត្វា យាវ ចក្កវាឡបរិយន្តា ឥតរា សព្វេ សត្តា ឥមេ សត្តា អបាទា វា ទ្វិបាទា វា ចតុប្បាទា វា ពហុប្បាទា

បក្ខិមេហិ វា ជលេហិ វា ថលេហិ វា អន្តលិក្ខេហិ វា តេ ច សព្វេ សត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, ទីឃាយុកា ហោន្តុ, អរោគា ហោន្តុ,សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។

*ចាតុម្មហារាជិកាទេវតាទាំងឡាយ តាវត្តឹសទេវតាទាំងឡាយ យាមាទេវតាទាំងឡាយ តុសិតទេវតាទាំងឡាយ និម្មានរតិទេវតាទាំងឡាយ បរនិម្មិតវសវត្តិទេវតាទាំងឡាយ រហូតដល់ព្រហ្មលោក គឺព្រហ្មបារិសជ្ជាទាំងឡាយ ព្រហ្មបុរោហិតាទាំងឡាយ មហាព្រហ្មាទាំងឡាយ ព្រហ្មបរិត្តាភាទាំងឡាយ ព្រហ្មអប្បមាណាភាទាំងឡាយ ព្រហ្មអាភស្សរាទាំងឡាយ ព្រហ្មបរិត្តសុភាទាំងឡាយ ព្រហ្មអប្បមាណសុភាទាំងឡាយ ព្រហ្មសុភាកិណ្ហកាទាំងឡាយ ព្រហ្មវេហប្ផលាទាំងឡាយ ព្រហ្មអសញ្ញីសត្វទាំងឡាយ ព្រហ្មអវិហាទាំងឡាយ ព្រហ្មអតប្បាទាំងឡាយ ព្រហ្មសុទស្សាទាំងឡាយ ព្រហ្មសុទស្សីទាំងឡាយ ព្រហ្មអកនិដ្ឋកៈទាំងឡាយ ព្រហ្មអាកាសានញ្ចាយតនៈទាំងឡាយ ព្រហ្មវិញ្ញាណញ្ចាយតនៈទាំងឡាយ ព្រហ្មអាកិញ្ចញ្ញាយនតៈទាំងឡាយ ព្រហ្មនេវសញ្ញានាសញ្ញាយតនៈទាំងឡាយ តាំងពីមហាព្រហ្មរហូតមកផ្ទៃផែនដី មិនលះបង់ដោយជុំវិញនៃភព រហូតទីបំផុតនៃចក្កវាឡ សត្វទាំងឡាយដែលនៅក្នុងភពដទៃក្តី សត្វទាំងឡាយទាំងពួង ដែលមិនមានជើងក្តី ជើងពីរក្តី ជើងបួនក្តី ជើងច្រើនក្តី សត្វស្វាបក្តី សត្វគោកក្តី សត្វទឹកក្តី សត្វ*

*អាកាសក្តី សត្វទាំងឡាយទាំងពួងនោះ សូមកុំមានពៀរនឹងគ្នា សូមឲ្យបាននូវសេចក្តីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្តីព្រួយចំបែង សូមឲ្យមានអាយុវែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខតរៀងទៅ ។*

ឥមេ និរយេ អដ្ឋ និរយេសុ សញ្ជីវេសុ កាឡសុត្តេសុ សង្ឃាតេសុ រោរុវេសុ មហារោរុវេសុ តាបនេសុ មហាតាបនេសុ អវីចីសុ មហាអវីចីសុ លោហកុម្ភីសុ មហាលោហកុម្ភីសុ សិម្ពលិរុក្ខេ វា ខារនទិយំ វា អង្គារបព្វតេ វា អយគុឡេ វា ថុសេ វា សុក្ខេ វា យន្តចាសាណេ វា អយំ មហាបថវី យាវ សោឡសនិរយេសុ អដ្ឋ មហានិរយេសុ សព្វេ តេ និរយេសុ សត្តា លោកន្តរនិរយេសុ សត្តា កាយកម្មេន វា វចីកម្មេន វា មនោកម្មេន វា អមាតាបិតោ អលេណតោ អសរណោតោ

*សត្វទាំងឡាយទាំងពួង ដែលស្ថិតនៅក្នុងនរក ១៦ រណ្តៅ ក្នុងនរក ៨ រណ្តៅ និងក្នុងលោកន្តរនរក មានសញ្ជីវនរក កាឡសុត្តនរក សង្ឃាតនរក រោរុវនរក មហារោរុវនរក តាបននរក មហាតាបននរក អវិចីនរក មហាអវិចីនរក លោហកុម្ភីនរក មហាលោហកុម្ភីនរក ដែលស្ថិតនៅដើមរកាក្តី ស្ទឹងដីប្រៃក្តី ភ្នំភ្លើងក្តី ដុំដែកក្តី អង្កាមក្តី ទីស្ងួតក្តី គ្រឿងយន្តថ្មក្តី ជាអ្នក*

*មិនមានមាតាបិតា មិនមានទីពូន មិនមានទីពឹង ព្រោះកាយកម្ម វចីកម្ម និង មនោកម្មរបស់ខ្លួន (ដែលជាទុច្ចរិត)*

**មម បុញ្ញានុភាវេន មម មេត្តានុភាវេន មម ករុណានុ–ភាវេន មម មុទិតានុភាវេន មម ឧបេក្ខានុភាវេន** *ដោយអានុភាពនៃបុណ្យរបស់ខ្ញុំ ដោយអានុភាពនៃមេត្តារបស់ខ្ញុំ ដោយអានុភាពនៃករុណារបស់ខ្ញុំ ដោយអានុភាពនៃមុទិតារបស់ខ្ញុំ ដោយអានុភាពនៃឧបេក្ខារបស់ខ្ញុំ* **សព្វេ តេ និរយកសត្តា អវេរា ហោន្តុ, សុខិតា ហោន្តុ, និទ្ទុក្ខា ហោន្តុ, អព្យាបជ្ឈា ហោន្តុ, អនីឃា ហោន្តុ, អរោគា ហោន្តុ, សម្បត្តីហិ សមិជ្ឈន្តុ, សុខី អត្តានំ បរិហរន្តុ ។** *សត្វនរកទាំងឡាយទាំងពួងនោះ សូមកុំមានពៀរនឹងគ្នា សូមឲ្យបានទូវសេចក្ដីសុខ ឲ្យប្រាសចាកទុក្ខ កុំព្យាបាទគ្នា កុំមានសេចក្ដីព្រួយចំបែង កុំឲ្យមានរោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួន ឲ្យជាសុខតរៀងទៅ ។*

**មហាមេត្តាគាថា និដ្ឋិតោ ។**

# មេត្តាសូត្រ

ឯវម្មេ សុតំ សូត្រនេះមានឈ្មោះថា មេត្តាសូត្រ គឺខ្ញុំឈ្មោះអានន្ទ បានស្តាប់មកយ៉ាងនេះថា ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ក្នុងទីនោះឯងព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ភគវា ឯតទវោច ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា មេត្តាយ ភិក្ខវេ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អដ្ឋានិសំសា ចាដិកង្ខា។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យច្រើន ចំរើនធ្វើឲ្យរឿយៗ ធ្វើឲ្យដូចយាន ធ្វើឲ្យជាទីនៅ បានតាំងទុករឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ មានអានិសង្ស ៨ ប្រការជាប្រាកដ ។ កតមេ អដ្ឋ? អានិសង្ស ៨ ប្រការ តើដូចម្តេចខ្លះ ? សុខំ សុបតិ ដេកលក់ ជាសុខ ១ សុខំ បដិពុជ្ឈតិ ភ្ញាក់ឡើងជាសុខ ១ ន បាបកំ សុបិនំ បស្សតិ មិនឃើញនូវសុបិនអាក្រក់ ១ មនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់នៃពួកមនុស្ស ១ អមនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់នៃពួកអមនុស្ស ១ ទេវតា រក្ខន្តិ ពួកទេវតា តែងរក្សា ១ នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ

*ភ្លើងក្តី ថ្នាំពិសក្តី សស្ត្រាវុធក្តី មិនប៉ះពាល់នូវបុគ្គលនោះ ១* ឧត្តរឹ អប្បដិ-
វិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ *កាលបើ មិនទាន់បានគុណវិសេស
ដ៏ខ្ពង់ខ្ពស់ទេ រមែងទៅកើតក្នុងព្រហ្មលោក ១* ។ មេត្តាយ ភិក្ខវេ ចេតោ-
វិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ
វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឥមេ អដ្ឋានិសំសា
បាដិកង្ខាតិ *ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យ
ថ្មីក ចំរើនធ្វើឲ្យរឿយ ៗ ធ្វើឲ្យដូចយាន ធ្វើឲ្យជាទីនៅ បានតាំងទុករឿយ ៗ
បានសន្សំ បានប្រារព្ធល្អហើយ រមែងមានអានិសង្ស ៨ ប្រការជាប្រាកដ* ។

យោ ច មេត្តំ ភាវយតិ អប្បមាណំ បដិស្សតោ
តនូ សំយោជនា ហោន្តិ បស្សតោ ឧបធិក្ខយំ ។

*បុគ្គលដែលនឹករលឹកចំពោះ ចំរើននូវមេត្តា ប្រមាណមិនបាន
ពិចារណាឃើញនូវការអស់ទៅនៃឧបធិក្កិលេស សំយោជនៈ
ទាំងឡាយក៏ស្រាលស្តើង* (បាកខន្ធសន្តោន) ។

ឯកម្បិ ចេ បាណមទុដ្ឋចិត្តោ
មេត្តាយតិ កុសលី តេន ហោតិ
សព្វេ ច បាណេ មនសានុកម្បី
បហូតមរិយោ បករោតិ បុញ្ញំ។

*បើបុគ្គលមានចិត្តមិនប្រទូស្តសត្វណាមួយ ឈ្មោះ
ថាជាប់មេត្តា កុសលក៏រមែងកើតមាន ដោយហេតុ
នោះ ចំណែកព្រះអរិយៈមានចិត្តអនុគ្រោះសត្វទាំង
ឡាយទាំងពួង តែងធ្វើបុណ្យច្រើន* ។

យេ សត្តសណ្ឌំ បថវឹ វិជេត្វា
រាជិសយោ យជមានា អនុបរិយគា
អស្សមេធំ បុរិសមេធំ
សម្មាបាសំ វាជបេយ្យំ និរគ្គឡំ។

ពួកស្ដេចណាដែលប្រាកដដូចជាឥសី បានឈ្នះនូវ
ផែនដីដែលពាសពេញដោយមនុស្ស សត្វ កាលឲ្យ
ទាន ប្រព្រឹត្តរឿយ ៗ (ដោយសង្គហវត្ថុ ៤ ប្រការ )
គឺឈ្លាសវៃក្នុងការទំនុកបម្រុងធញ្ញជាតិ ១
ឈ្លាសវៃក្នុងការទំនុកបម្រុងមនុស្ស ១ ការចង
ចិត្តមនុស្ស ១ ពោលពាក្យជាទីស្រឡាញ់ ១ មិន
បាច់ប្រើទុកទ្វារផ្ទះឡើយ ។

មេត្តស្ស ចិត្តស្ស សុភាវិតស្ស
កលម្បិ តេ នានុភវន្តិ សោឡសិំ
ចន្ទប្បភា តារគណាវ សព្វេ
យថា ន អគ្ឃន្តិ កលម្បិ សោឡសិំ ។

ការឲ្យទានទាំងឡាយនោះ ក៏មិនដល់នូវចំណិតក្នុង
ចំណែក១៦ នៃមេត្តាចិត្ត ដែលបានអប់រំហើយ
ដូចជារស្មីព្រះចន្ទ្រនិងពួកផ្កាយទាំងពួង ។

យោ ន ហន្តិ ន ឃាតេតិ    ន ជិនាតិ ន ជាបយេ
មេត្តំ សោ សព្វភូតានំ    វេរំ តស្ស ន កេនចីតិ ។

បុគ្គលណា ជាអ្នកមានចំណែកនៃមេត្តាសមាធិចិត្ត ចំពោះពួកសត្វទាំងអស់ មិនបៀតបៀន មិនសម្លាប់ មិនធ្វើសេចក្តីវិនាសដល់សត្វដទៃដោយខ្លួនឯង មិនប្រើអ្នកដទៃឲ្យធ្វើសេចក្តីវិនាសដល់សត្វដទៃ វេរារបស់បុគ្គលនោះ មិនមានដោយហេតុណាមួយឡើយ។

មេត្តាសុត្តំ និដ្ឋិតំ ចប់មេត្តាសូត្រ។

## ឧដ្ឋានសូត្រ

ឧដ្ឋហថ និសីទថ   កោ អត្ថោ សុបិតេន វោ
អាតុរានញ្ហិ កា និទ្ទា   សល្លវិទ្ធាន រុប្បតំ។

*( ព្រះដ៏មានព្រះភាគទ្រង់ត្រាស់និងពួកភិក្ខុយ៉ាងនេះថា )*

*អ្នកទាំងឡាយចូរក្រោក ( ចូរអង្គុយចម្រើនកម្មដ្ឋាន )*
*ប្រយោជន៍អ្វី ដោយការដេកលក់របស់អ្នកទាំងឡាយ*
*ព្រោះថា អ្នកទាំងឡាយ ឈឺជានិច្ច ត្រូវសរគឺរាគាទិកិ្កលេស*
*ចាក់ដោតហើយ កំពុងតែលំបាក ម្ដេចក៏នៅដេកលក់ ។*

ឧដ្ឋហថ និសីទថ   ទឡ្ហំ សិក្ខថ សន្តិយា
មា វោ បមត្តេ វិញ្ញាយ   មច្ចុរាជា អមោហយិត្ថ វសានុគេ។

*អ្នកទាំងឡាយ ចូរក្រោកអង្គុយ ចូរសិក្សាឲ្យមាំមួន ដើម្បីសេចក្ដី*
*ស្ងប់ កុំឲ្យមច្ចុរាជបានដឹងនូវអ្នកទាំងឡាយថា ជាអ្នកប្រមាទ*
*ហើយធ្វើឲ្យវង្វេង លុះក្នុងអំណាចនៃខ្លួនឡើយ ។*

យាយ ទេវា មនុស្សា ច សិតា តិដ្ឋន្តិ អត្ថិកា
តរថេតំ វិសត្តិកំ   ខណោ វោ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា។

*ពួកទេវតានិងមនុស្ស ត្រូវការនឹងអារម្មណ៍ជាដើម អាស្រ័យ*
*ជាប់នៅ ( ក្នុងអារម្មណ៍នោះ ) ព្រោះតណ្ហាណា អ្នកទាំងឡាយ*
*ចូរឆ្លងនូវតណ្ហាជាគ្រឿងផ្សាយនុ៎ះ កុំឲ្យខណៈកន្លងផុតនូវអ្នក*

*ទាំងឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្លងហើយ រមែងសោកណែនណាន់ ក្នុងនរក ។*

បមាទោ រជោ បមាទោ　　បមាទានុបតិតោ រជោ
អប្បមាទេន វិជ្ជាយ　　អព្វូហេ សល្លមត្តនោតិ ។

*សេចក្តីប្រមាទ ជាធូលី ធូលីធ្លាក់ចុះតាមសេចក្តីប្រមាទ ព្រោះតែសេចក្តីប្រមាទ កុលបុត្រដកចោលនូវសរគឺរាគាទិក្កិលេសរបស់ខ្លួនបាន ដោយវិជ្ជា គឺអាសវក្ខយញ្ញាណ ព្រោះតែសេចក្តីមិនប្រមាទ ។*

ឧដ្ឋានសុត្តំ និដ្ឋិតំ *ចប់ឧដ្ឋានសូត្រ ។*

## សរណទីបិកាគាថា

ពហុំ វេ សរណំ យន្តិ  បព្វតានិ វនានិ ច

អារាមរុក្ខចេត្យានិ  មនុស្សា ភយតជ្ជិតា ។

*មនុស្សទាំងឡាយមានចំនួនច្រើន កាលដែលភ័យគ្របសង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាមនិងដើមឈើ ដែលជាចេតិយទាំងឡាយខ្លះ ជាទីពឹង ។*

នេតំ ខោ សរណំ ខេមំ  នេតំ សរណមុត្តមំ

នេតំ សរណមាគម្ម  សព្វទុក្ខា បមុច្ចតិ ។

*ទីពឹងនុ៎ះឯង មិនមែនជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះមិនមែនជាទីពឹងដ៏ឧត្តម បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះទេ ។*

យោ ច ពុទ្ធញ្ច ធម្មញ្ច  សង្ឃញ្ច សរណំ គតោ

ចត្តារិ អរិយសច្ចានិ  សម្មប្បញ្ញាយ បស្សតិ

ទុក្ខំ ទុក្ខសមុប្បាទំ  ទុក្ខស្ស ច អតិក្កមំ

អរិយញ្ចដ្ឋង្គិកំ មគ្គំ  ទុក្ខូបសមគាមិនំ ។

*បុគ្គលណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរឭក ហើយឃើញនូវអរិយសច្ចទាំង៤ គឺសេចក្តីទុក្ខ១ សមុទ័យជាដែន*

*កើតឡើងព្រមនៃសេចក្តីទុក្ខ១ និរោធជាទីកន្លងបង់នូវសេចក្តីទុក្ខ១ មគ្គមានអង្គ៨ដ៏ប្រសើរ ដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ជាស្ពានរម្ងាប់បង់នូវសេចក្តីទុក្ខ១ ដោយប្រាជ្ញដ៏ត្រូវ*

ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ

ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ។

*ទីពឹងនុ៎ះឯងជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះជាទីពឹងដ៏ឧត្តម (របស់បុគ្គលនោះ) បុគ្គល រមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។*

## ធលិទ្ទសុត្តគាថា

យស្ស សទ្ធា តថាគតេ អចលា សុបតិដ្ឋិតា *បុគ្គលឯណា (មាន)សេចក្តីជឿតម្កល់មាំ ឥតកម្រើក ចំពោះព្រះតថាគត*

សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ *បុគ្គលឯណា (មាន)សីលដ៏ល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈទាំងឡាយលោកសរសើរហើយ*

សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ *បុគ្គលឯណា មានសេចក្តីជ្រះថ្លាចំពោះព្រះសង្ឃផង មានសេចក្តីយល់ឃើញដ៏ត្រូវត្រង់ផង*

**អធលិន្ទោតិ តំ អាហុ អមោឃន្តស្ស ជីវិតំ** *បណ្ឌិតទាំងឡាយលោកហៅបុគ្គលនោះថា មិនមែនជាអ្នកទ័លក្រឡើយ ជីវិតរបស់បុគ្គលនោះ មិនមែនសោះសូនឥតប្រយោជន៍ឡើយ*

**តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ**

**អនុយុញ្ជេថ មេធាវី សរំ ពុទ្ធាន សាសនំ។**

*ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញា កាលរឭកឃើញនូវសាសនា គឺពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ ក៏គួរប្រកបរឿយៗ នូវសេចក្តីជឿផង នូវសីលផង នូវសេចក្តីជ្រះថ្លាផង នូវកិរិយាឃើញនូវធម៌ផង ។*

## គារវសុត្តគាថា

**យេ ច អតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា**

**យោ ចេតរហិ សម្ពុទ្ធោ ពហុន្នំ សោកនាសនោ។**

*ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់កន្លងហួសទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលមិនទាន់បានត្រាស់ក្តី ព្រះសម្មាសម្ពុទ្ធអង្គឯណា ជាអ្នកញុាំងសេចក្តីសោករបស់ជនទាំងឡាយច្រើន ឲ្យវិនាសទៅ (មាន) ក្នុងកាលឥឡូវនេះក្តី ។*

**សព្វេ សទ្ធម្មគរុនោ** *ព្រះសម្មាសម្ពុទ្ធ (ទាំងឡាយនោះ) គ្រប់ព្រះ*

*អង្គ សុទ្ធតែមានសេចក្តីគោរពចំពោះព្រះសទ្ធម្ម*

វិហរឹសុ វិហាតិ ច *ព្រះអង្គគង់នៅរួចទៅហើយក្តី គង់នៅក្នុងកាលឥឡូវនេះក្តី*

អថាបិ វិហរិស្សន្តិ *នឹងគង់នៅតទៅទៀតក្តី*

ឯសា ពុទ្ធាន ធម្មតា *កិរិយាបែបនេះ ជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ*

តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា

សទ្ធម្មោ គរុកាតព្វោ សរំ ពុទ្ធាន សាសនំ។

*ក៏ព្រោះហេតុដូច្នោះ បុគ្គលអ្នកស្រឡាញ់នូវខ្លួន អ្នកប្រាថ្នានូវការៈជាធំ កាលរឭកឃើញនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គួរតែធ្វើនូវសេចក្តីគោរពចំពោះព្រះសទ្ធម្ម ។*

**បព្វតោបមសុត្តគាថា**

យថាបិ សេលា វិបុលា នភំ អាហច្ច បព្វតា

សមន្តា អនុបរិយេយ្យុំ និប្បោថេន្តា ចតុទ្ទិសា។

*ប្រសិនណាបើភ្នំទាំងឡាយ សុទ្ធសឹងតែថ្មដ៏ខ្ពស់ពេញអាកាស រមៀលកិននូវសត្វទាំងឡាយ ដែលមកដោយជុំវិញទាំង៤ទិស យ៉ាងណាមិញ ។*

ឯវំ ជរា ច មច្ចុ ច អធិវត្តន្តិ បាណិនោ

ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ទេ ចណ្ឌាលបុក្កុសេ។

*សេចក្តីចាស់ សេចក្តីស្លាប់ តែងគ្របសង្កត់នូវសត្វទាំងឡាយ (មិនរើសមុខ) ទោះជាក្សត្រក៏ដោយ ជាព្រាហ្មណ៍ក៏ដោយ ជាអ្នកជំនួញក៏ដោយ ជាពួកគូលីក៏ដោយ ជាពួកចណ្ឌាលក៏ដោយ ជាអ្នកចាក់សំរាមចោលក៏ដោយ យ៉ាងនោះឯង*

**ន កញ្ចិ បរិវជ្ជេតិ សព្វមេវាភិមទ្ទតិ** *ឥតមានវៀរលែងនូវបុគ្គលណាមួយឡើយ តែងគ្របសង្កត់ញាំញីនូវសត្វទាំងអស់មិនឲ្យសល់មួយ*

**ន តត្ថ ហត្ថីនំ ភូមិ** *ភូមិនៃដំរីទាំងឡាយ មិនមានក្នុងជរានិងមរណៈនោះទេ*

**ន រថានំ ន បត្តិយា** *(ភូមិ)នៃរថទាំងឡាយក៏មិនមាន ទាំង(ភូមិ)នៃពលថ្មើរជើងទាំងឡាយក៏មិនមាន (ក្នុងជរានិងមរណៈនោះឡើយ)*

**ន ចាបិ មន្តយុទ្ធេន សក្កា ជេតុំ ធនេន វា** *ម្យ៉ាងទៀត ឥតមានអ្នកណាមួយនឹងឈ្នះ (នូវជរានិងមរណៈនោះ) ដោយការតតាំងច្បាំងដោយនូវវេទមន្ត ឬដោយនូវទ្រព្យសម្បត្តិបានឡើយ*

**តស្មា ហិ បណ្ឌិតោ បោសោ**

**សម្បស្សំ អត្ថមត្តនោ**

**ពុទ្ធេ ធម្មេ ច សង្ឃេ ច**

**ធីរោ សទ្ធំ និវេសយេ។**

*ព្រោះហេតុនោះ បុរសជាបណ្ឌិតអ្នកមានប្រាជ្ញា កាលឃើញនូវ*

ប្រយោជន៍របស់ខ្លួន ក៏គួរនឹងបណ្ដុះនូវសទ្ធា ចំពោះព្រះពុទ្ធនិងព្រះធម៌ និង ព្រះសង្ឃ

**យោ ធម្មចារី កាយេន វាចាយ ឧទ ចេតសា** បុគ្គលណាមួយ ជាអ្នកប្រព្រឹត្តនូវធម៌ ដោយកាយ ដោយវាចា ឬដោយចិត្ត

**ឥធេវ នំ បសំសន្តិ** បណ្ឌិតទាំងឡាយ តែងសរសើរនូវបុគ្គលនោះក្នុងលោកនេះឯង

**បេច្ច សគ្គេ បមោទតិ** បុគ្គលនោះលុះទៅកាន់បរលោកនាយហើយ តែងត្រេកអររីករាយក្នុងស្ថានសួគ៌ទៀត ។

**សំវេជនីយគាថា**

**ន គាមធម្មោ និគមស្ស ធម្មោ**

**ន ចាបិ យំ ឯកកុលស្ស ធម្មោ**

**សព្វស្ស លោកស្ស សទេវកស្ស**

**ឯសេវ ធម្មោ យទិទំ អនិច្ចតា។**

ធម៌ណាដែលមានឈ្មោះថា អនិច្ចតាធម៌ គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយៗ)ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយៗ) ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនទេ អនិច្ចតាធម៌នុ៎ះ ជាធម៌សម្រាប់មនុស្សសត្វព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។

ន គាមធម្មោ និគមស្ស ធម្មោ

ន ចាបិ យំ ឯកកុលស្ស ធម្មោ

សព្វស្ស លោកស្ស សទេវកស្ស

ឯសេវ ធម្មោ យទិទញ្ញ ទុក្ខតា។

*ធម៌ណាដែលមានឈ្មោះថាទុក្ខតាធម៌ គឺសភាពជាទុក្ខ ទុក្ខតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយៗ)ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយៗ) ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនទេ អនិច្ចតាធម៌នុ៎ះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។*

ន គាមធម្មោ និគមស្ស ធម្មោ

ន ចាបិ យំ ឯកកុលស្ស ធម្មោ

សព្វស្ស លោកស្ស សទេវកស្ស

ឯសេវ ធម្មោ យទិទំ អនត្តតា។

*ធម៌ណាដែលមានឈ្មោះថាអនត្តាធម៌ គឺសភាពមិនមែនជារបស់ខ្លួន អនត្តាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយៗ)ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយៗ) ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនទេ អនិច្ចតាធម៌នុ៎ះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ។*

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ**

**ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ។**

*សង្ខារធម៌ទាំងឡាយមិនទៀងមែនពិត មានកិរិយាកើតឡើង និងវិនាសទៅវិញជាធម្មតា រមែងកើតឡើងហើយរលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង។*

**សព្វេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ**

**យថាកម្មំ គមិស្សន្តិ បុញ្ញបាបផលូបគា**

**និរយំ បាបកម្មន្តា បុញ្ញកម្មា ច សុគតឹ។**

*សត្វទាំងឡាយទៀងតែនឹងស្លាប់គ្រប់ៗគ្នា ព្រោះថាជីវិត(របស់សត្វទាំងឡាយ) សុទ្ធតែមានសេចក្តីស្លាប់នៅខាងចុងបំផុតគ្រប់ៗប្រាណ (ម្យ៉ាងទៀត)សត្វទាំងឡាយរមែងកាន់យកនូវផលបុណ្យផលបាប ហើយនឹងទៅតាមយថាកម្ម គឺទៅតាមគួរដល់អំពើល្អនិងអាក្រក់ដែលខ្លួនបានធ្វើ អ្នកដែលធ្វើបាប តែងធ្លាក់ទៅសោយទុក្ខក្នុងនរក ចំណែកខាងអ្នកដែលធ្វើបុណ្យ តែងឡើងទៅកាន់សុគតិភព ។*

**តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ**

**បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ។**

ព្រោះហេតុដូច្នោះហើយ សាធុជនអ្នកមានចំណង់ចង់បានសេចក្តីសុខ (ដល់ខ្លួន) គួរតែប្រញាប់ប្រញាល់ធ្វើអំពើបុណ្យ ដែលជាគុណ គឺអ្នកប្រាជ្ញតែងរាប់អាន ឲ្យបានជាកិច្ច គឺខ្លួនត្រូវកសាងសន្សំ (គ្រាន់នឹងបានជាទីពឹង) នៅក្នុងភពខាងនាយ (ព្រោះថា) បុណ្យទាំងឡាយតែងជាទីពឹងពំនាក់របស់សត្វទាំងឡាយក្នុងបរលោក ។

ផេណបិណ្ឌូបមំ រូបំ វេទនា បុព្វុឡូបមា

មរីចិកូបមា សញ្ញា សង្ខារា កទលូបមា

មាយូបមញ្ច វិញ្ញាណំ ទេសិតាទិច្ចពន្ធុនា។

រូបមានសេចក្តីប្រៀបធៀបនឹងដុំនៃពពុះទឹក វេទនាមានសេចក្តីប្រៀបធៀបនឹងក្រពេញទឹក ដែលប៉ោងឡើងព្រួចៗ សញ្ញាមានសេចក្តីប្រៀបធៀបនឹងដើមចេក វិញ្ញាណមានសេចក្តីប្រៀបធៀបនឹងកលមាយា (សេចក្តីប្រៀបធៀបនៃខន្ធទាំង៥នេះ) គឺព្រះសម្ពុទ្ធមានផៅពង្សដ៏ខ្ពង់ខ្ពស់ដូចជាព្រះអាទិត្យ ព្រះអង្គទ្រង់សម្តែងហើយ ។

អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ

ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ។

កាយនេះមិននៅយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅប្រាសហើយ ជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសន្កត់នៅលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ

អបវិទ្ធោ តទា សេតិ និរត្ថំវ កលិង្គរំ។

*អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយនេះទៅក្នុងកាលណាហើយ(កាយនេះក៏ដល់នូវសេចក្តីមិនគួរនឹងទុកដាក់ឲ្យនៅលើផ្ទះសម្បែងបានឡើយ) គេតែងនាំយកទៅចោលឲ្យដេកនៅ (លើផែនដី) ក្នុងកាលនោះឯងដូចជាអង្កត់ឧសរកប្រយោជន៍គ្មានឡើយ ។*

យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ

ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ។

*គង្វាលគោ កៀងគោទាំងឡាយទៅកាន់ទីគោចរដោយអាជ្ញា គឺដំបង ឬរំពាត់យ៉ាងណាមិញ ជរាគឺសេចក្តីទ្រុឌទ្រោមគ្រាំគ្រា និងមច្ចុរាជគឺសេចក្តីស្លាប់ ក៏កៀងទៅនូវអាយុ របស់សត្វទាំងឡាយយ៉ាងនោះឯង ។*

**សេចក្តីជាស់តឿនរបស់ព្រះពុទ្ធបរមគ្រូ**

អថ ខោ ភគវា យេនុបដ្ឋានសាលា តេនុបសង្កមិ; ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ

*គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់និងភិក្ខុទាំងឡាយថា*

តស្មាតិហ ភិក្ខវេ យេ តេ មយា ធម្មា អភិញ្ញា ទេសិតា, តេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា,

យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ, តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ *ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់ សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។*

កតមេ ច តេ ភិក្ខវេ ធម្មា មយា អភិញ្ញា ទេសិតា, យេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា, យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ, តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ សេយ្យថិទំ ? *ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសំដែងហើយ ដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយ ៗ ដោយប្រការដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បី*

*ប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសំដែងហើយ ដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃហើយសេព ចម្រើន ធ្វើឲ្យរឿយ ៗ ដោយប្រការដូច្នោះ ។ តើធម៌ទាំងឡាយនោះតើដូចម្តេច ?*

ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ។ ឥមេ ខោ តេ ភិក្ខវេ ធម្មា មយា អភិញ្ញា ទេសិតា, យេ វោ សាធុកំ ឧគ្គហេត្វា អាសេវិតព្វា ភាវេតព្វា ពហុលីកាតព្វា, យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ, តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ *គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បី*

*សេចក្ដីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសំដែងហើយដោយបញ្ញាដ៏ឧត្ដម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើឲ្យរឿយ ៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។*

**អថ ខោ ភគវា ភិក្ខូ អាមន្តេសិ** *គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ៖*

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ, វយធម្មា សង្ខារា, អប្បមាទេន សម្បាទេថ ។**

*ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយ មានសេចក្ដីវិនាសទៅជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួង ឲ្យសម្រេចដោយសេចក្ដីមិនប្រមាទចុះ ។*

## មន្តគាថាសេកទឹកមន្ត

(០) ឥមំ តថា អធិដ្ឋាមិ សិធានកោធកំ
យថា អវមង្គលានំ ឥមំ ហោតុ វិសោធយេ។

*យើងអធិដ្ឋាននូវទឹកសេកដែលជាគ្រឿងផ្ងូតនេះ*
*ដោយសេចក្តីបរិសុទ្ធរបស់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ*
*យ៉ាងណា ទឹកសេកដែលជាគ្រឿងផ្ងូតនេះ ចូរជាគ្រឿង*
*ជម្រះនូវអវមង្គលទាំងឡាយ យ៉ាងនោះដែរ ។*

(១) កាយេ អវមង្គលានិ សព្ពានិមិស្សតានិ វា
សព្វនយន្តុវនាយន្តុ វិគច្ឆន្តុ អសេសតោ ។

*អវមង្គលទាំងឡាយនិងឧបទ្រពទាំងឡាយទាំងពួង*
*ដែលលាយក្នុងកាយនេះ ចូរអន្តរធាន វិនាសទៅ*
*កុំបីមានសេសសល់ឡើយ ។*

(២) ភយូបទ្ទវុបសគ្គា អវមង្គលបច្ចយា
អន្តរាយា ច អពេគា ច អវមង្គលសម្ភវា
មាហេសុំ សព្វថា សត្តេ ឥមិនា វសិនា យតំ
សព្វត្ថ សោត្ថិភាវោ ច ជីឃាយុ តាជិកប្បិ ច
សម្ភវេវ សមិជ្ឈន្តុ ឥមិនា វសិនា យតំ ។

*សេចក្តីខ្លាច និងការរវើរវាយ និងឧបសគ្គ ដែលមាន*
*អវមង្គលជាបច្ច័យក្តី អន្តរាយនិងរោគទាំងឡាយដែលកើត*
*ព្រម ព្រោះអវមង្គលទាំងឡាយក្តី ចូរកុំមានដោយប្រការ*

*ទាំងពួងឡើយ សូមសិរីសួស្តី មានអាយុវែងជាដើម*
*ចូរសម្រេចដោយប្រពៃចុះ ។*

(០) **កិត្តិ សិទ្ធិ កម្មសិទ្ធិ វិជិសិទ្ធយត្តសិទ្ធិ ច**
**អារម្ភសិទ្ធិយោ ហោន្តុ ឥមិណារ សិណាយតំ**[1]**។**
*កិត្តិសិទ្ធិ កម្មសិទ្ធិ វិធិសិទ្ធិ យត្តសិទ្ធិ និងអារម្ភសិទ្ធិ*
*ចូរសម្រេចដោយប្រពៃចុះ ។*

(៣) **តតោ តតោ អាគច្ឆន្តា បច្ចត្ថិកានមិទ្ធិយោ**
**មា កាត្តចិ សម្ជុស្សឹសុ ឥមិណា រសិណា យតំ ។**
*សេចក្តីប្រាថ្នារបស់សត្រូវទាំងឡាយដែលមានមកពីទីនោះៗ*
*ចូរកុំបានពាល់ត្រូវឡើយ ដោយអំណាចនៃគ្រឿងផ្លូតនេះ*
*ចូរសម្រេចដោយប្រពៃចុះ ។*

(៤) **យេបិ តេ ទុក្កហាគោសា អាកាសតោបិ អាគតា**
**ផុដ្ឋា ចាបន្តរាយន្តុ ឥមិណា រសិណា យតំ ។**
*ទោសទាំងឡាយមានបាបគ្រោះ សូម្បីជាវត្ថុណាមួយ*
*ដែលមកហើយអំពីអាកាស ពាល់ត្រូវចូលក្តី*
*ទោសបាបគ្រោះទាំងឡាយនោះ ចូរអន្តរធានវិនាសទៅ*
*ដោយគ្រឿងផ្លូតនេះ ។*

(០) **សិទ្ធមត្ថុ សិទ្ធមត្ថុ សិទ្ធមត្ថុ ឥទំ ផលំ**
**ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ ។**

---

[1]*កាលធ្វើពិធីសេកទឹកសម្រាប់ខ្លួនឯង គួរបន្ថែមគាថានេះ ។ តែបើធ្វើពិធីឲ្យអ្នកដទៃ មិនចាំបាច់ សូត្យសេកគាថានេះទេ ។*

សូមផលនៃចិត្តដែលជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ ផលនេះ
ចូរជាផលសម្រេច ចូរជាផលសម្រេច ចូរជាផលសម្រេច ។

**គោលពិធីរបស់មន្ត**

គាថាទី (១) ឲ្យជម្រះបណ្ដេញអវមង្គលនិងចង្រៃទាំងពួង
គាថាទី (២) ការពារភ័យ អន្តរាយទាំងពួង
គាថាទី (៣) ការពារភូតបិសាច ខ្មោច ព្រាយ អាថាន់
បញ្ចៀសអំពើផ្សេងៗ
គាថាទី (៤) កែដួងជតាមិនល្អ គ្រោះអាក្រក់
ផ្កាយបាបគ្រោះឲ្យទោស រាហូ កាឡកិណី ឃាតគ្រោះ ឧក្បាត
ផ្កាយដុះកន្ទុយ និងផ្កាយធ្លាក់ជាដើម ។

**ពិធីការ**

ត្រូវរកផ្តិលមួយ ជាផ្តិលសម្រឹទ្ធិ ឬផ្តិលស្ពាន់យ៉ាងណាមួយ ដាក់ទឹកពេញក្នុងផ្តិល ។ បន្ទាប់មកយកផ្កាឈូក ១៩ ទង តម្កល់បូជាព្រះរតនត្រ័យ និងមានផ្កាឈូកចំនួន ៩ ទង តម្កល់ទុកក្នុងផ្តិលទឹក តំណាងដល់នវលោកុត្តរធម៌ ។ រួចជាស្រេចអង្គុយភាវនាចម្រើនមេត្តា ឲ្យជាបុរេចារិក ហើយមានមេត្តាជាផ្ទៃឲ្យអ្នកនោះបានទទួលនូវសេចក្តីសុខ រួចផុតចាកទុក្ខ ហើយស្វាធ្យាយព្រះពុទ្ធគុណ (**ឥតិបិ សោ ភគវា អរហំ..ភគវាតិ** ) ស្វាធ្យាយព្រះធម្មគុណ (**ស្វាក្ខាតោ ភគវតា ធម្មោ...**) ស្វាធ្យាយព្រះសង្ឃគុណ (**សុបដិបន្នោ ភគវតោ សាវកសង្ឃោ..**) ហើយ ចាប់ផ្តើម ស្វាធ្យាយគាថាសេកទឹកមន្តនេះចុះ ។ បើអាចគួរស្វាធ្យាយ ព្រះបរិត្តដទៃទៀត មានឫទ្ធានុភាពខ្លាំងក្លាបន្ថែមទៀត ។

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុង-
 រឿងក្នុងលោក


ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់

នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោម៖

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ៖ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែល៖ maha.panna@gmail.com

គេហទំព័រ៖ http://www.mahapanna.org

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

## Taking Refuge with a mind of Bodhichitta

In the Buddha, the Dharma and the Sangha,
I shall always take refuge
Until the attainment of full awakening.

Through the merit of practicing generosity
and other perfections,
May I swiftly accomplish Buddhahood,
And benefit of all sentient beings.

## The Prayers of the Bodhisattvas

With a wish to awaken all beings,
I shall always go for refuge
To the Buddha, Dharma, and Sangha,
Until I attain full enlightenment.

Possessing compassion and wisdom,
Today, in the Buddha's presence,
I sincerely generate
the supreme mind of Bodhichitta
For the benefit of all sentient beings.

"As long as space endures,
As long as sentient beings dwell,
Until then, may I too remain
To dispel the miseries of all sentient beings."

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

## DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《柬埔寨文：Collection of Daily Chanting, 日常課誦本》

財團法人佛陀教育基金會 印贈

台北市杭州南路一段五十五號十一樓

Printed and donated for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website: http://www.budaedu.org

Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

Printed in Taiwan

3,000 copies; September 2015

CA052 - 13500